ចំពោះសាធារណជនទូទៅ

# វចនានុក្រមស្ដីពីភាពស៊ាំនឹងឱសថប្រឆាំងរោគ

AMR dictionary



COMRU. wellcome Angkor Hospital for Children University of Oxford

GREENPEACE

## បុព្វកថា

វចនានុក្រម ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ (The AMR dictionary) (មានឯកសារជា PDF និងលើគេហទំព័រ www.amrdiciontary.net) មានគោលបំណងផ្ដល់ការអប់រំ និងជាព័ត៌មានតែប៉ុណ្ណោះ។ អ្នកអានអាចទទួលបាននូវចំណុចមួយចំនួនមាននៅក្នុងមាតិការបស់វចនានុក្រមនេះ រួមមានចំណុចគួរយល់ដឹង និងវីដេអូណែនាំខ្លីៗ តែព័ត៌មានទាំងនេះមិនមែនសម្រាប់យកមកជំនួសដំបូន្មានរបស់អ្នកមានជំនាញខាងវេជ្ជសាស្ត្រ ការធ្វើរោគវិនិច្ឆ័យ ឬការព្យាបាលនោះទេ។

ប្រសិនអ្នកឈឺ ពួកយើងសូមណែនាំអ្នកឱ្យទៅជួប និងទទួលយកដំបូន្មានពីវេជ្ជបណ្ឌិត ឬបុគ្គលិកសុខាភិបាលដែលនៅជិត ព្រមទាំងសួរនាំពួកគេពីស្ថានភាពសុខភាពរបស់អ្នក។ អ្នកមិនត្រូវធ្វេសប្រហែសក្នុងការស្វែងរកដំបូន្មានពីគ្រូពេទ្យ ឬក៏ពន្យាពេលស្វែងរកការថែទាំសុខភាពរបស់អ្នកនោះទេ។

ចំណេះដឹង ការស្រាវជ្រាវ និងការអនុវត្តន៍នៅក្នុងវិស័យនេះកំពុងតែមានការផ្លាស់ប្ដូរឥតឈប់ឈរ។ វចនានុក្រមភាពស៊ាំនឹងឱសថប្រឆាំងមេរោគ នឹងបន្តកែសម្រួលលើ

មាតិកាជារឿយៗ ទាំងនៅក្នុងឯកសារPDF និងគេហទំព័រ។ សូមអ្នកអានទាំងអស់ ត្រូវទុកចិត្តចំពោះអនុសាសន៍របស់បុគ្គលិកសុខាភិបាលនៅក្នុងប្រទេស និងឯកសារផ្លូវការស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគដែលចេញដោយរដ្ឋាភិបាល អំពីការវាយតម្លៃព័ត៌មាន ហើយក៏ត្រូវយកចិត្តទុកដាក់លើសុវត្ថិភាពរបស់លោកអ្នក និងមនុស្សផ្សេងៗទៀតផងដែរ។

វចនានុក្រមនេះមិនបានទទួលការឧបត្ថម្ភពីស្ថាប័នឯកជន ឬក្រុមហ៊ុនឱសថណានោះទេ ហើយក៏មិនមានការផ្សព្វផ្សាយពាណិជ្ជកម្មអ្វីនោះដែរ។ វចនានុក្រម **ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ** នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ស្ថិតនៅក្រោមអាជ្ញាប័ណ្ណ (CC BY license (Creative Common Attribution 4.0)

ដោយសេចក្តីគោរពរាប់អាន
ក្រុមការងារបកប្រែវចនានុក្រម **ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ**
យើងមានបណ្តាញទំនាក់ទំនងច្រើនភាសា
១) ប្រសិនបើលោកអ្នកមានសំនួរពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ សូមចូលទស្សនាគេហទំព័ររបស់យើងដោយសេរី www.amrdictionary.net ឬទំព័រហ្វេសប៊ុក fb.me/amrdictionary

២) ប្រសិនបើលោកអ្នកចង់ផ្តល់មតិរិះគន់ ស្ថាបនាផ្សេងៗ សូមចូលតាមរយៈ QR code

(https://www.surveymonkey.com/r/amrdictionary)

៣) ប្រសិនបើលោកអ្នកមានយោបល់ ឬសំណូមពរអំពីវចនានុក្រមនេះ ឬមាតិការបស់វចនានុក្រម លោកអ្នកអាចផ្ញើសារអេឡិចត្រូនិចដោយផ្ទាល់មក ravikanya@tropmedres.ac និង direk@tropmedres.ac ។

## តារាងមាតិកា

**ជំពូក១៖ តើអ្វីជាភាពស៊ាំនឹងឱសថប្រឆាំងមេរោគ?..........1**
ការស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) ..............................1
អតិសុខុមកាយ ..............................................................6
ឱសថអង់ទីប៊ីយោទិក (ថ្នាំផ្សះ) ......................................10
ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ....14
ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក ..............................20
**ជំពូក២៖ ភាពស៊ាំ..............................................................26**
ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក (ភាពស៊ាំនឹងថ្នាំផ្សះ)26
ការបង្ករោគដោយមេរោគស៊ាំឱសថ (DRI) .........................31
មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (Superbug)..........................................................................34
ដែលស៊ាំឱសថច្រើនប្រភេទ (MDR) ..................................38
**ជំពូក៣៖ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក..................44**
ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគ ..........44
ដែលទិញ ឬលក់ដោយគ្មានវេជ្ជបញ្ជា (OTC) ....................49
ការប្រើប្រាស់ឱសថដែលសមស្រប (RDU).........................54
**ជំពូក៤៖ ឱសថអង់ទីប៊ីយោទិកប្រើក្នុងផ្នែកបសុសត្វ.....58**
ដែលផ្តល់ចំណីសត្វមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក ..................................................................................58
សារធាតុដែលគ្មានផ្ទុកឱសថអង់ទីប៊ីយោទិក .................63
ឱសថអង់ទីប៊ីយោទិកដែលសំខាន់ចាំបាច់ (CIA) ...........67
ការចិញ្ចឹមសត្វដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិក (RWA) ..........................................................................72
**ជំពូក៥៖ យុទ្ធនាការប្រយុទ្ធប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ......................................................................76**
សប្តាហ៍យល់ដឹងអំពីឱសថអង់ទីប៊ីយោទិកសកល.........76
ស្នាមជើង ឱសថអង់ទីប៊ីយោទិក (Antibiotic Footprint) ..........................................................................79
ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដ៏ឆ្លាតវៃ .................83
ការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ..........87
**ជំពូក៦៖ មីក្រុប..........................................................90**
បាក់តេរី...........................................................................90
ផ្សិត ................................................................................94
វីរុស .................................................................................97
**សេចក្តីថ្លែងអំណរគុណ................................................100**
បកប្រែនិងកែសម្រួលវចនានុក្រមជាភាសាខ្មែរដោយ 100

## ជំពូក១៖ តើអ្វីជាភាពស៊ាំនឹងឱសថប្រឆាំងមេរោគ?

### ការស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR)

*(នាម)* លទ្ធភាពរបស់អតិសុខុមកាយ (រួមមាន៖ បាក់តេរី វីរុស ផ្សិត និងប៉ារ៉ាស៊ីត) ដែលអាចបញ្ឈប់សកម្មភាព  ឱសថសម្លាប់មេរោគ (រួមមាន៖ ឱសថអង់ទីប៊ីយោទិក ឱសថប្រឆាំងផ្សិត ឱសថប្រឆាំងវីរុស និងឱសថប្រឆាំងប៉ារ៉ាស៊ីត) ពីការប្រឆាំងលើពួកវា។

> “បាក់តេរីដែលវិវត្តខ្លួនទៅជាស៊ាំនឹងឱសថប្រឆាំងមេរោគ ចំពោះឱសថអង់ទីប៊ីយោទិកសំខាន់ៗប្រើទូទៅ សព្វថ្ងៃនេះ ហៅថា ‘superbugs’។”

> “ការស៊ាំនឹងឱសថប្រឆាំងមេរោគ (AMR) បានគំរាមកំហែងទៅលើប្រសិទ្ធភាពលើការបង្ការ និងព្យាបាលនៃការបង្ករោគដោយបាក់តេរី ប៉ារ៉ាស៊ីត វីរុស និងផ្សិត ដែលកើនឡើងឥតឈប់ឈរ។” [១]

## ពាក្យស្រដៀង

### ដែលស៊ាំនឹងឱសថប្រឆាំងមេរោគ

*(គុណនាម)* ដែលមានលទ្ធភាពបញ្ឈប់សកម្មភាពរបស់ឱសថប្រឆាំងមេរោគ ពីការប្រឆាំងមកលើពួកវា។

“មេរោគដែលស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាពពួកមេរោគដែលមានលទ្ធភាពអាចបញ្ឈប់សកម្មភាពរបស់ឱសថប្រឆាំងមេរោគ ដែលមានឥទ្ធិពលមកលើពួកវា។”

“ការបង្ករោគពីមេរោគស៊ាំនឹងឱសថប្រឆាំងមេរោគ គឺជាការបង្ករោគដោយមេរោគដែលស៊ាំនឹងឱសថប្រឆាំងមេរោគ។”

“រៀងរាល់ឆ្នាំ មនុស្សប្រមាណជាង ៧០០ ០០០នាក់ បានស្លាប់នៅជុំវិញពិភពលោក បណ្តាលមកពីការបង្ករោគដោយមេរោគស៊ាំនឹងឱសថប្រឆាំងមេរោ

## ចំណុចគួរស្វែងយល់៖

## តើការស៊ាំនឹងឱសថប្រឆាំងមេរោគ ជាការព្រួយបារម្ភរបស់សកលលោកដែរឬទេ?

ឱសថសង្គ្រោះជីវិតជាច្រើនប្រភេទ ប្រើសម្រាប់ប្រឆាំងនឹងជំងឺឆ្លង ដែលកំពុងតែបាត់បង់ប្រសិទ្ធភាពជាបណ្តើរៗ ដោយសារបាក់តេរី និងពពួកមីក្រុបផ្សេងៗ បានវិវត្តទៅជាស៊ាំទៅនឹងឱសថទាំងនោះ។ [១] [២]ជាលទ្ធផល បណ្តាលឱ្យអ្នកជំងឺឈឺរយៈពេលយូរ ពិការភាព និងមរណភាព។ ប្រសិនបើមិនចាត់វិធានការណាមួយទេ សូម្បីតែការបង្ករោគធម្មតាក៏អាចគំរាមកំហែងដល់អាយុជីវិតដែរ ហាក់ដូចជាវិលត្រលប់ទៅរកសម័យកាលដ៏គួរឱ្យខ្លាចមួយដែលគ្មានឱសថអង់ទីប៊ីយោទិកសម្រាប់ព្យាបាល។

ប្រសិនបើយើងទាំងអស់គ្នាមិនផ្លាស់ប្តូរ នោះ! នៅពេលមានការវះកាត់ទូទៅ និងសម្រាលកូន អាចមានការប្រឈមខ្ពស់ រួមមាន៖ ទារក ម្តាយ និងអ្នកជំងឺជាច្រើន អាចស្លាប់ដោយសារតែការបង្ករោគដែលអាចបង្ការ និងព្យាបាលបាន។ [១]

តាមធម្មតាពួកមីក្រុបអាចសម្របខ្លួនរបស់វាដើម្បីរស់នៅក្នុងបរិស្ថាន។ ប៉ុន្តែ ពេលមនុស្សយើងប្រើប្រាស់  ឱសថប្រឆាំងមេរោគមិនបានត្រឹមត្រូវ ឬក៏លើសកម្រិត ដែលធ្វើឱ្យការផ្លាស់ប្តូរនេះ កាន់តែរហ័ស ហើយ ពួកមេរោគស៊ាំនឹងឱសថប្រឆាំងមេរោគក៏មានការកកើតកាន់តែច្រើន ដែលបណ្តាលឱ្យការព្យាបាលកាន់តែពិបាក។

ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងមិនត្រឹមត្រូវ បានកើតឡើងទាំងលើមនុស្ស និងសត្វ។ ជំងឺទូទៅដែលកើតលើមនុស្សដូចជា ផ្តាសាយធម្មតា និងផ្តាសាយធំ គឺបង្កដោយវីរុស ហើយមិនអាចព្យាបាលដោយឱសថអង់ទី

ប៊ី-យោទិកបាននោះទេ។ ក៏ប៉ុន្តែ មនុស្សជាច្រើននៅលើពិភពលោកបានលេបឱសថអង់ទីប៊ីយោទិក ទាំងមិនចាំបាច់ នៅពេលពួកគេមានជំងឺផ្ដាសាយធម្មតា ឬផ្ដាសាយធំជាដើម។ ឱសថអង់ទីប៊ីយោទិក ក៏ត្រូវបានប្រើយ៉ាងសន្ធឹកសន្ធាប់នៅក្នុងកសិដ្ឋានចិញ្ចឹមសត្វទូទាំងពិភពលោក។ ឱសថអង់ទីប៊ីយោទិកមួយភាគធំ កំពុងតែត្រូវបានប្រើប្រាស់ដោយមិនបានត្រឹមត្រូវនៅលើយសត្វពាហនៈ ដើម្បីបង្កើនការលូតលាស់ ឬបង្ការជំងឺ។

ជារៀងរាល់ឆ្នាំ មនុស្សជាង ៧00 000នាក់ បានស្លាប់នៅជុំវិញពិភពលោក ដោយសារតែការបង្ករោគដោយសារមេរោគដែលស៊ាំនឹងឱសថប្រឆាំងមេរោគ។ ប្រសិនបើយើងមិនចាត់វិធានការអ្វីនោះទេ ការស្លាប់ដែលបណ្ដាលមកពី ភាពស៊ាំនឹងឱសថប្រឆាំងមេរោគអាចកើនដល់ ១0 000 000នាក់ ក្នុងមួយឆ្នាំ គិតត្រឹមឆ្នាំ២0៥0។ យើងត្រូវកាត់បន្ថយការប្រឈមនឹងបាក់តេរីដែលវិវត្តខ្លួនទៅជាស៊ាំនឹងឱសថ។ ដំបូងគឺការកាត់បន្ថយការប្រើប្រាស់ឱសថ អង់ទីប៊ីយោទិកមិនត្រឹមត្រូវ ឬប្រើលើសកម្រិត ។ [៣]

ចូរស្វែងយល់បន្ថែមឱ្យបានច្រើនពីរបៀបដែលជួយប្រយុទ្ធប្រឆាំងនឹងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ចំណេះដឹងពីឱសថអង់ទីប៊ីយោទិក និងយុទ្ធនាការប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។

ពាក្យទាក់ទង៖ អតិសុខុមកាយ ឱសថប្រឆាំងមេរោគ។

## សេចក្ដីយោង

[1] WHO (2018). "Antimicrobial resistance". *WHO*

[2] CDC (2018). "About Antimicrobial Resistance- Antibiotic/Antimicrobial resistance- CDC". *CDC.gov*

[3] O'Niell J. (2016). "Tackling Drug-Resistant Infections Globally: Final Report and Recommendations.- The review on Antimicrobial Resistance." *amr-review.org*

## អតិសុខុមកាយ

*(នាម)* ជាភាវៈតូចល្អិតៗដែលមិនអាចមើលឃើញដោយភ្នែកទទេ និងត្រូវការមីក្រូទស្សន៍ ដើម្បីមើលវា។

> "អតិសុខុមកាយត្រូវបានរកឃើញនិងរស់នៅជុំវិញយើង ដូចជាមាននៅលើស្បែក និងនៅក្នុងខ្លួនរបស់យើងជាដើម។"

> "អតិសុខុមកាយខ្លះអាចបង្ករោគ និងបង្កជំងឺ ហៅថា មេរោគ (germs) ។ ទោះបីជាយ៉ាងណាក៏ដោយ មិនមែនអតិសុខុមកាយទាំងអស់សុទ្ធតែបង្កជំងឺនោះទេ ពួកវាខ្លះក៏ជួយដល់យើងផងដែរ"

### ពាក្យស្រដៀង

**មីក្រុប** (Microbe)

*(នាម)* ពាក្យកាត់ របស់ពាក្យអតិសុខុមកាយ (microorganism)។

**មេរោគ** (Germ)

*(នាម)* អតិសុខុមកាយដែលបណ្ដាលឱ្យមានការបង្ករោគ និងជំងឺ។



## ចំណុចគួរស្វែងយល់

### ប្រភេទ និងលទ្ធភាពរបស់មីក្រុប

មីក្រុបមានបួនក្រុមធំៗដូចជាផ្សិត បាក់តេរី វីរុស និងប៉ារ៉ាស៊ីត។ ជាទូទៅ ផ្សិតមានទំហំធំជាងគេបង្អស់ នៅក្នុងក្រុមរបស់ មីក្រុប។ ប្រសិនបើមានផ្សិតតែមួយហៅថា ហ្វាំងហ្គីស (Fungus) ។ ជាទូទៅបាក់តេរី គឺតូចជាងផ្សិត និងមិនមានកោសិកាណ្វៃយ៉ូ (Nucleus)។ ប្រសិនបើមានបាក់តេរីតែមួយគេហៅថា បាក់តេរៀម (Bacterium)។ វីរុស មានតំហំតូចជាងគេបំផុតនៅក្នុងក្រុមរបស់មីក្រុប ហើយវាមិនមានកោសិកាណ្វៃយ៉ូ(Nucleus) និងជញ្ជាំងកោសិកានោះទេ។ វីរុសអាចបង្ករកំណើតបានតែនៅក្នុងកោសិកា ឬសរីរាង្គមានជីវិតតែប៉ុណ្ណោះ។ ប៉ារ៉ាស៊ីតតូចល្អិតដែលបង្កជំងឺញឹកញាប់គឺ ប៉ារ៉ាស៊ីតគ្រុនចាញ់។

ផ្សិតធំ និងផ្សិតផ្ស័ត្រ គឺជាក្រុមរបស់ផ្សិត និងពួកព្រូនមួយចំនួន គឺជាក្រុមប៉ារ៉ាស៊ីត។ ប៉ុន្តែពួកវាមិនមែនជាពួកមីក្រុបទេ ព្រោះពួកវាធំៗ ហើយបង្កើតឡើងដោយកោសិកាជាច្រើន។

មីក្រុបមាននៅគ្រប់ទីកន្លែង។ តាមការប៉ាន់ប្រមាណបាក់តេរីអាចមានរហូតដល់១០ពាន់លាន ក្នុងដីមួយក្រាម (១០ពាន់លាន=១០ ០០០ ០០០ ០០០) ។[១] នៅក្នុងរាងកាយ

របស់យើង អាចមានបាក់តេរីរហូតដល់ ៣៩ពាន់កោដិ (៣៩ពាន់កោដិ= ៣៩ ០០០ ០០០ ០០០ ០០០)។ [២]

ប៉ារ៉ាស៊ីតគ្រុនចាញ់ អាចលាក់ខ្លួននៅក្នុងរាងកាយរបស់មនុស្ស វាបំបែកខ្លួននៅក្នុងកោសិកាឈាម ហើយអាចចម្លងពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀតបាន នៅពេលមូសខាំមនុស្សដែលមានជំងឺគ្រុនចាញ់ ឬផ្ទុកប៉ារ៉ាស៊ីត ហើយទៅខាំមនុស្សម្នាក់ផ្សេងទៀត។

មីក្រុបទាំងអស់ អាចមានលទ្ធភាពទប់ទល់ទៅនឹងប្រសិទ្ធភាពរបស់ឱសថ តែមួយចំនួនអាចទប់ទល់បានទាំងស្រុងពីការប្រឆាំងទៅលើពួកវា។ ពួកវាហៅថា មេរោគស៊ាំនឹងឱសថ។[៣]

**ឧទាហរណ៍** ឱសថអង់ទីប៊ីយោទិកបានប្រើប្រាស់មិនត្រឹមត្រូវលើមនុស្ស និងសត្វ ហើយឱសថអង់ទីប៊ីយោទិកទាំងនោះសាយភាយបន្តិចម្តងៗទៅក្នុងបរិស្ថាន។ បាក់តេរីដែលនៅក្នុងខ្លួនរបស់មនុស្ស សត្វ និងបរិស្ថាន ដែលធ្លាប់បានព្យាបាល ឬប៉ះពាល់ជាមួយឱសថអង់ទីប៊ីយោទិកពីមុន អាចទៅជាស៊ាំជាមួយឱសថអង់ទីប៊ីយោទិកបាន។ បាក់តេរីដែលស៊ាំឱសថទាំងនោះអាចចម្លង និងបង្កជំងឺដែលបណ្តាលឱ្យស្លាប់ទៀតផង។

**ពាក្យទាក់ទង៖** ភាពស៊ាំនឹងឱសថប្រឆាំងមេរោគ ឱសថប្រឆាំងមេរោគ និងអតិសុខុមកាយ

## សេចក្តីយោង

[1] Ingham E.R. (2018). "Soil Biology- Chapter 3: Bacteria". *extension.illinois.edu*

[2] Sender R., Milo R., and Fuchs S. (2016). "Revised estimates for the number of human and bacteria cells in the body." *PLOS Biology.* 14(8): e1002533. doi: 10.1371/journal.pbio.1002533

[3] WHO (2015). "Global Action Plan on Antimicrobial Resistance". *wpro.who.int*

## ឱសថអង់ទីប៊ីយោទិក (ផ្ទាំផ្សះ)

*(នាម)* ជាសារធាតុ ឬឱសថ(**ឧ**. ឱសថប៉េនីស៊ីលីន (penicillin))ដែលអាចសម្លាប់ ឬបញ្ឈប់ការលូតលាស់របស់បាក់តេរីបាន។

> “វេជ្ជបណ្ឌិតបានប្រាប់ខ្ញុំថា ខ្ញុំមិនត្រូវការឱសថអង់ទីប៊ីយោទិកទេ។ ឱសថអង់ទីប៊ីយោទិក វាប្រឆាំងបានតែជាមួយបាក់តេរីតែប៉ុណ្ណោះ។”

> “ឱសថអង់ទីប៊ីយោទិកមិនអាចសម្លាប់វីរុសបានទេ ដូចជាផ្តាសាយធម្មតា ឬផ្តាសាយធំជាដើម។ ការប្រើ ឱសថអង់ទីប៊ីយោទិកសម្រាប់ជំងឺដែលបង្កដោយវីរុស វាមិនបានធ្វើឱ្យអ្នកធូរស្បើយ ឬអាចត្រលប់ទៅធ្វើការបានឆាប់រហ័សជាងមិនប្រើនោះទេ។”

*(គុណនាម)* ដែលផ្ទុកនូវសារធាតុ ឬឱសថដែលអាចសម្លាប់ ឬបញ្ឈប់ការលូតលាស់របស់បាក់តេរីបាន។ ដែលពាក់ព័ន្ធជាមួយឱសថអង់ទីប៊ីយោទិក។

> “គាត់ឈឺធ្ងន់ដោយសារបាក់តេរី ហើយត្រូវការព្យាបាលយូរជាមួយឱសថអង់ទីប៊ីយោទិក។”



## ចំណុចគួរស្វែងយល់

### គ្រោះមហន្តរាយដ៏មានសក្តានុពលនៅពេលអនាគត

ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ជាបញ្ហាមួយដ៏ធ្ងន់ធ្ងរដែលគំរាមកំហែងទៅលើសុខភាពសាធារណៈនៅលើពិភពលោក វាមានសក្តានុពលអាចសម្លាប់មនុស្សរាប់លាននាក់ និងជះឥទ្ធិពលអវិជ្ជមានដល់សេដ្ឋកិច្ចពិភពលោកទៀតផង។[១] អង្គការសហប្រជាជាតិ (UN) បានអនុម័តសេចក្តីប្រកាសពីគោលនយោបាយជាន់ខ្ពស់ពីការប្តេជ្ញាចិត្តដើម្បីដោះស្រាយបញ្ហានៃការកើនឡើងនៃចំនួនការបង្ករោគដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក។[២]

ឱសថអង់ទីប៊ីយោទិកដែលប្រើប្រាស់សម្រាប់ព្យាបាលជំងឺបង្កដោយបាក់តេរីទូទៅ ដូចជាជំងឺរលាកសួត រលាកផ្លូវទឹកម៉ូត្រ និងរលាកកោសិកា គឺកំពុងតែបាត់បង់ប្រសិទ្ធភាពក្នុងការព្យាបាល។ អគ្គនាយក នៃអង្គការសុខភាពពិភពលោកមានប្រសាសន៍ថា៖ វាចាំបាច់ដែលអ្នកទទួលនិងអ្នកផ្តល់សេវាកម្មសុខភាពគួរកាត់បន្ថយការពឹងផ្អែកលើឱសថអង់ទីប៊ីយោទិក

ពីព្រោះថា នៅពេលអនាគតដ៏ខ្លីទៀតនេះពួកយើង នឹងលែងមានឱសថអង់ទីប៊ីយោទិកដែលមានប្រសិទ្ធភាព

សម្រាប់ផ្ដល់ឱ្យអ្នកជំងឺ និងបម្រើក្នុងវិស័យវេជ្ជសាស្ត្រទៀតហើយ។

គាត់បានព្រមានថា៖ “ដោយផ្អែកលើនិន្នាការបច្ចុប្បន្ន ជំងឺទូទៅមួយចំនួនដូចជាជំងឺប្រមេះ (gonorrhea)និង អាចក្លាយទៅជាជំងឺដែលមិនអាចព្យាបាលបាន” ។ “វេជ្ជបណ្ឌិតនៅពេលជួបជាមួយអ្នកជំងឺ អាចនិយាយបានត្រឹមថា ខ្ញុំសូមទោស ខ្ញុំមិនមានឱសថអ្វីសម្រាប់ព្យាបាលអ្នកបានទៀតនោះទេ។”

នេះគឺជាការព្រួយបារម្ភណ៍ដ៏ធំធេងមួយ និងជាបញ្ហាដែលអាចប៉ះពាល់ដល់ពួកយើង និងគ្រួសាររបស់ពួកយើង។ នេះជាឧទាហរណ៍ដ៏សំខាន់មួយ ករណីការសម្រាលកូននៅពេលមានបាក់តេរីស៊ាំនឹងឱសថអង់ទីប៊ីយោទិក ពួកគេអាចនឹងមានហានិភ័យខ្ពស់។ មាតា និងទារក អាចប្រឈមការស្លាប់ខ្ពស់ ដោយសារការបង្ករោគដោយបាក់តេរី។

**ពាក្យទាក់ទង៖** ឱសថប្រឆាំងមេរោគ ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ

## សេចក្ដីយោង

[1] O'Niell J. (2016). “Tackling Drug-Resistant Infections Globally: Final Report and Recommendations.- The review on Antimicrobial Resistance.” *amr-review.org*

[2] The Guardian, UK, 2016 Sep 21, and WHO 'Birth in a time of antibiotic-resistant bacteria', 2016 Aug 29

## ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ

*(នាម)* សកម្មភាពនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ និងមិនសមស្របនឹងអាការៈជំងឺ។

"ការប្រើឱសថអង់ទីប៊ីយោទិកដែលមានឥទ្ធិពលសម្លាប់ទូលំទូលាយ នៅពេលដែលប្រើមិនត្រូវទិសដៅព្យាបាល គឺជាឧទាហរណ៍នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ។"

"ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវដើម្បីព្យាបាលជំងឺដែលបង្កដោយវីរុសដែលជាសះស្បើយដោយខ្លួនឯង ដូចជាផ្តាសាយធម្មតាជាដើម ដែលជាការចំណាយយ៉ាងច្រើនរបស់សង្គមទៅលើវា។"

## ពាក្យស្រដៀង

**ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ**

(Antibiotic abuse)

*(នាម)* សកម្មភាពនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ ឬមិនសមស្រប។



## ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត

(Antibiotic overuse)

*(នាម)* សកម្មភាពនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកច្រើនពេក ឬញឹកញាប់ពេក។

"ការប្រើឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ ឬលើសកម្រិតគឺមិនងាយស្រួលក្នុងការគ្រប់គ្រងទេ។"

"ភាពស៊ាំឱសថអង់ទីប៊ីយោទិកត្រូវបានពន្លឿនដោយសារការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ ឬការប្រើលើសកម្រិត ក៏ដូចជាខ្វះការយល់ដឹងពីការបង្ការ ឬការគ្រប់គ្រងការបង្ក

## ចំណុចគួរស្វែងយល់

**តើអ្នកកំពុងតែធ្វើឱ្យខ្លួនឯង និងអ្នកដទៃ មានហានិភ័យដោយសារការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវដែរឬទេ?**

ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ ឬប្រើប្រាស់លើសកម្រិត គឺមានគ្រោះថ្នាក់ខ្លាំងណាស់។ ការលេបឱសថអង់ទីប៊ីយោទិកសម្រាប់ព្យាបាលផ្តាសាយ ឬជំងឺបង្ក

ដោយវីរុសផ្សេងទៀត វាគ្មានប្រសិទ្ធភាពនោះទេ ប៉ុន្តែវាផ្ដល់ផលរំខានដែលមានគ្រោះថ្នាក់មកវិញ។ បន្ថែមពីនេះទៅទៀត ប្រសិនបើសកម្មភាពបែបនេះកើតឡើងយូរៗទៅ វានឹងធ្វើឱ្យបាក់តេរីកាន់តែពិបាកព្យាបាល។ បាក់តេរីទាំងនោះ អាចបង្កជំងឺមកលើយើង គ្រួសាររបស់យើង ឬមនុស្សផ្សេងៗទៀតនៅក្នុងសង្គម។

**តើសកម្មភាពអ្វីខ្លះ ដែលរាប់បញ្ចូលថាជាការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ?**

[១] ប្រើឱសថអង់ទីប៊ីយោទិកសម្រាប់ព្យាបាលផ្ដាសាយធម្មតា ឬផ្ដាសាយធំ

[២] ការប្រើឱសថអង់ទីប៊ីយោទិកដោយគ្មានការណែនាំពីបុគ្គលិកសុខាភិបាលដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ

ឬស្នើសុំឱសថអង់ទីប៊ីយោទិកពីបុគ្គលិកសុខាភិបាលដែលខុសពីការណែនាំរបស់ពួកគេ

[៣] មិនបានលេបឱសថអង់ទីប៊ីយោទិកឱ្យចប់គ្រប់ចំនួនតាមវេជ្ជបញ្ជា

[៤] ចែកចាយឱសថអង់ទីប៊ីយោទិក ឱ្យអ្នកដទៃប្រើដែរ

[៥] ប្រើឱសថអង់ទីប៊ីយោទិកដែលសល់ពីលើកមុន

**តើខ្ញុំគួរតែធ្វើអ្វីខ្លះ?**

[១] សូមកុំប្រើឱសថអង់ទីប៊ីយោទិកសម្រាប់ព្យាបាលផ្ដាសាយធម្មតា ឬផ្ដាសាយធំ

[២] លេបឱសថអង់ទីប៊ីយោទិកតាមការណែនាំរបស់បុគ្គលិកសុខាភិបាលដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវ។

ឱ្យកាន់តែប្រាកដ អ្នកអាចសួរថា «តើតម្រូវឱ្យខ្ញុំលេបឱសថអង់ទីប៊ីយោទិកដែរឬទេ?»

[៣] លេបឱសថអង់ទីប៊ីយោទិករហូតដល់អស់តាមវេជ្ជបញ្ជា ទោះបីជាអ្នកធូរស្រាលហើយក៏ដោយ

[៤] សូមកុំចែករំលែកឱសថអង់ទីប៊ីយោទិកឱ្យអ្នកដទៃប្រើ

[៥] សូមកុំប្រើឱសថអង់ទីប៊ីយោទិកដែលសល់ពីលើកមុន

**ការយល់ខុសទូទៅពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ**

[១] **ខ្ញុំចង់លេបឱសថអង់ទីប៊ីយោទិក «ដើម្បីការពារក្នុងករណីដែលខ្ញុំនឹងអាចឈឺ»។**

**ចម្លើយ: ខុស** ផ្ដាសាយធម្មតា និងផ្ដាសាយធំ បង្កដោយវីរុស។ ជំងឺរាកស្រួចស្រាវភាគច្រើន មិនមែនបង្កដោយបាក់តេរីទេ។ ការលេបឱសថអង់ទីប៊ីយោទិកដោយគ្មានការណែនាំពីបុគ្គលិកសុខាភិបាលដែលមានអាជ្ញាប័ណ្ណត្រឹមត្រូវគឺកំពុងតែធ្វើឱ្យខ្លួនរបស់អ្នកប្រឈមទៅនឹងឥទ្ធិពលអាក្រក់ពីឱសថ ហើយធ្វើឱ្យអ្នកដទៃប្រឈមការឆ្លងរោគដោយបាក់តេរីដែលស៊ាំជាមួយឱសថអង់ទីប៊ីយោទិកដោយឥតប្រយោជន៍ទៅវិញ។

**[២] កាលពីមុនខ្ញុំលេបឱសថអង់ទីប៊ីយោទិកសម្រាប់ព្យាបាលផ្តាសាយធម្មតា ខ្ញុំមានអារម្មណ៍ថាឆាប់ធូរស្បើយលឿន។ ខ្ញុំនឹងលេបឱសថអង់ទីប៊ីយោទិកទៀត ពេលណាខ្ញុំមានជំងឺផ្តាសាយ។**

**ចម្លើយៈ ខុស** ផ្តាសាយធម្មតា និងផ្តាសាយធំ គឺបង្កដោយវីរុស ហើយមនុស្សភាគច្រើននឹងជាពីជំងឺមកវិញក្នុងរយៈពេលពី ៧ ទៅ ១០ថ្ងៃ។ អ្នកអាចធូរស្បើយដោយមិនបាច់លេបឱសថអង់ទីប៊ីយោទិក។ ឱសថអង់ទីប៊ីយោទិកមិនអាចសម្លាប់វីរុសបានទេ ហើយក៏មិនធ្វើឱ្យអ្នកបានធូរស្រាល ឬអាចឱ្យអ្នកទៅធ្វើការវិញបានឆាប់រហ័សដែរ។

**[៣] ពីមុនខ្ញុំលេបឱសថអង់ទីប៊ីយោទិក ហើយខ្ញុំមិនបានទទួលផលរំខានអ្វីពីឱសថផងហ្នឹង។ ដូច្នេះខ្ញុំក៏មិនបានទទួលផលរំខានអ្វីពីឱសថដែរ នៅពេលខ្ញុំលេបម្តងនេះ។**

**ចម្លើយៈ ខុស** នៅពេលដែលអ្នកលេបឱសថអង់ទីប៊ីយោទិក វានៅតែអាចមានផលរំខានរបស់ឱសថកើតមានឡើងបាន ទោះបីជាពីមុនអ្នកធ្លាប់បានលេបហើយមិនមានបញ្ហាក៏ដោយ។ ការលេបឱសថអង់ទីប៊ីយោទិកម្តងហើយម្តងទៀត អាចធ្វើឱ្យកើនឡើងការប្រឈមនឹងផលរំខានមួយចំនួន ដូចជា ជំងឺរាក និងការបង្ករោគដោយមេរោគផ្សិតជាដើម។

**[៤] ទោះបីជាបាក់តេរីនៅក្នុងខ្លួនរបស់ខ្ញុំវាស៊ាំឱសថ ហើយខ្ញុំឈឺដោយសារវានោះ ខ្ញុំនៅតែអាចទិញឱសថអង់ទីប៊ី-យោទិកដែលខ្លាំងជាងមុនដើម្បីព្យាបាល។**

**ចម្លើយៈ ខុស** មានបាក់តេរីជាច្រើនដែលស៊ាំទៅនឹងឱសថជាច្រើនប្រភេទ។ បាក់តេរីមួយចំនួនទៀត មិនអាចព្យាបាលដោយឱសថអង់ទីប៊ីយោទិកដែលមាននាពេលបច្ចុប្បន្ននេះទេ។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ អាចធ្វើឱ្យកើនឡើងឱកាសនៃការបង្ករោគដោយបាក់តេរីដែលស៊ាំជាមួយឱសថគ្រប់មុខដែលកំពុងតែមាននៅពេលសព្វថ្ងៃនេះ។

**[៥] ទោះបីជាបាក់តេរីនៅក្នុងខ្លួនរបស់ខ្ញុំវាស៊ាំឱសថ ហើយខ្ញុំឈឺដោយសារវានោះ មានតែខ្ញុំទេដែលមានបញ្ហា ហើយខ្ញុំក៏មិនបានបង្កបញ្ហាដល់អ្នកដទៃដែរ**

**ចម្លើយៈ ខុស** បាក់តេរីដែលស៊ាំឱសថអង់ទីប៊ីយោទិកនៅក្នុងខ្លួនរបស់អ្នក មិនប្រាកដថាវាធ្វើឱ្យអ្នកមានគ្រោះថ្នាក់នោះទេ ប៉ុន្តែពួកវាអាចចម្លងទៅសមាជិកក្នុងគ្រួសាររបស់អ្នក បរិស្ថានជុំវិញ ឬទៅមនុស្សនៅក្នុងសង្គមទៀតផងដែរ។ ការប្រើឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ អាចបង្កគ្រោះថ្នាក់ដល់សង្គមទាំងមូលទៀតផង។

**ពាក្យទាក់ទងៈ** ចំណេះដឹងពីឱសថអង់ទីប៊ីយោទិក ការជ្រើសរើសឱសថអង់ទីប៊ីយោទិកដែលត្រឹមត្រូវ (antibiotic stewardship)

## ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក

*(នាម)* សមត្ថភាពក្នុងការយល់ដឹង វាយតម្លៃ និងអនុវត្តន៍តាមព័ត៌មានអំពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវរួមទាំងបង្ការភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក។

> "ដោយយោងតាមការស្ទង់មតិបានបង្ហាញថាអ្នកជំងឺច្រើនជាងពាក់កណ្តាលបានដឹងថា ឱសថអង់ទីប៊ីយោទិកមិនអាចសម្លាប់វីរុសបានទេ ប៉ុន្តែពួកគេនៅតែលេបឱសថអង់ទីប៊ីយោទិក « នៅរាល់ពេលឈឺ»។" [១]

> "ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកនៅមានកម្រិតខ្ពស់ និងចំណេះដឹងពីឱសថអង់ទីប៊ីយោទិកមានកម្រិតទាបចំពោះសាធារណជនទូទៅ គឺជាការជួបប្រសព្វគ្នាដ៏គ្រោះថ្នាក់មួយ។"

### ចំណុចគួរស្វែងយល់

### តើអ្នកយល់ដឹងកម្រិតណាអំពីឱសថអង់ទីប៊ីយោទិក?

យ៉ាងហោចណាស់ មនុស្សម្នាក់ៗបានប្រើឱសថអង់ទីប៊ីយោទិក១ដងដែរក្នុងមួយជិវិតរបស់ពួកគេ។ ទោះបីយ៉ាងណាក៏ដោយ ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកនៅតែបន្តជាបញ្ហាដល់ពិភពលោកទាំងមូល ដោយសារពុំទាន់យល់ច្បាស់ពីទំនាក់ទំនងរវាងខ្លួនមនុស្ស ឬបាក់តេរីដែលស៊ាំនឹងឱសថ។

នៅតែមានការយល់ច្រឡំពីភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកនឹងអ្វីដែលយើងអាចធ្វើបានដើម្បីបង្ការបញ្ហានេះ។ អង្គការសុខភាពពិភពលោកបានធ្វើការស្ទង់មតិជាសកលអំពី «ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក» ដោយមានអ្នកចូលរួមប្រមាណ ១០ ០០០នាក់ មកពីប្រទេសចំនួន១២ បានរកឃើញយ៉ាងច្បាស់ថា ពីរភាគបីនៃអ្នកចូលរួមសរុបមានកម្រិតនៃការយល់ដឹងទាប។[១] មួយភាគបីនៃអ្នកចូលរួមបានយល់ខុសថា វាមិនអីទេ បើឈប់លេបឱសថអង់ទីប៊ីយោទិកនៅពេលណាបានធូរស្បើយពីជំងឺ ដោយមិនបាច់លេបគ្រប់តាមវេជ្ជបញ្ជាក៏បានដែរ។ ប្រហែលបីភាគបួននៃអ្នកចូលរួម មានជំនឿខុសដែលបានឱ្យនិយមន័យ «ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក» ថា ខ្លួនរបស់មនុស្សជាអ្នកជាស៊ាំនឹងឱសថអង់ទីប៊ីយោទិក។[១]

មនុស្សជាច្រើនកំពុងតែមិនអើពើពីបញ្ហាការស៊ាំនឹងឱសថអង់ទីប៊ីយោទិក។ ការយល់ខុសភាគច្រើនដែលកើតមាននោះ គឺម្នាក់ៗយល់ថាបញ្ហាភាពស៊ាំនេះគឺកើតមានលើតែអ្នកលេបឱសថអង់ទីប៊ីយោទិកសកម្មតែប៉ុណ្ណោះ។[២] ការពិតទៅបាក់តេរី ដែលអាចវិវត្តខ្លួនឱ្យស៊ាំនឹងឱសថ

អង់ទីប៊ីយោទិក គឺជាបាក់តេរីដែលអាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន។ នេះមានន័យថា មនុស្សគ្រប់គ្នាគឺងាយនឹងទទួលរងនូវការឆ្លងនូវបាក់តេរីដែលស៊ាំជាមួយឱសថ ទោះបីជាអ្នកមិនលេបឱសថអង់ទីប៊ីយោទិកក៏ដោយ។

**ប្រអប់១៖ តើអ្នកដឹងបានប៉ុណ្ណាពីការប្រើប្រាស់ដែលត្រឹមត្រូវ និងភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក?**

១. ឱសថអង់ទីប៊ីយោទិកអាចព្យាបាល ផ្តាសាយធម្មតាបាន **[ត្រូវ ឬខុស]**

២. ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក អាចកើតមាននៅពេលរាងកាយរបស់ខ្ញុំបានស៊ាំទៅនឹងឱសថអង់ទីប៊ី-យោទិក **[ត្រូវ ឬខុស]**

៣. ឱសថអង់ទីប៊ីយោទិកដែលអ្នកលេបអាចបណ្តាលឱ្យមានភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក **[ត្រូវ ឬខុស]**

៤. ឱសថអង់ទីប៊ីយោទិកប្រើនៅក្នុងកសិកម្មចិញ្ចឹមសត្វ អាចបណ្តាលឱ្យមានភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក **[ត្រូវ ឬខុស]**

៥. ការបង្ករោគដោយបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក អាចចម្លងទៅមនុស្សបាន ដោយសារការប៉ះពាល់ជាមួយមនុស្សដែលមានផ្ទុកបាក់តេរីស៊ាំជាមួយឱសថអង់ទីប៊ីយោទិក **[ត្រូវ ឬខុស]**

៦. ការបង្ករោគដោយបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក អាចចម្លងទៅមនុស្សបាន ដោយសារការប៉ះពាល់ជាមួយសត្វមានជីវិត អាហារ ឬទឹក ដែលមានផ្ទុកបាក់តេរីស៊ាំជាមួយឱសថអង់ទីប៊ីយោទិក **[ត្រូវ ឬខុស]**

៧. ការចាក់វ៉ាក់សាំងរបស់ខ្ញុំត្រូវតាមពេលកំណត់ ខ្ញុំលាងដៃបានត្រឹមត្រូវ និងទៀងទាត់ រក្សាភាពស្អាត និងអនាម័យ ខ្លួនប្រាណ អាចជួយដល់ពិភពលោកឱ្យឆ្ពោះទៅរកដំណោះស្រាយ ភាពស៊ាំរបស់ឱសថអង់ទីប៊ី-យោទិក **[ត្រូវ ឬខុស]**

**កំណែ:**

១. **ខុស**. ផ្តាសាយធម្មតា ភាគច្រើនបង្កដោយវីរុស។ ឱសថអង់ទីប៊ីយោទិកមិនអាចសម្លាប់វីរុសបានទេ ហើយក៏មិនកាត់បន្ថយរយៈពេលឈឺ ឬធ្វើឱ្យរោគសញ្ញាបានធូរស្រាលដែរ។ អានបន្ថែមសូមចុច **ទីនេះ។**

២. **ខុស**. ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត មិនបណ្តាលឱ្យរាងកាយរបស់អ្នកស៊ាំជាមួយឱសថអង់ទីប៊ីយោទិកនោះទេ។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត បណ្តាលឱ្យបាក់តេរីស៊ាំទៅនឹងឱ

សថអង់ទីប៊ីយោទិក ហើយបាក់តេរីដែលស៊ាំឱសថអង់ទីប៊ីយោទិកនោះ អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន។
**៣. ត្រឹមត្រូវ.** ចូរអានបន្ថែមពីរបៀបនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ដែលអាចនាំទៅរកភាពស៊ាំនឹងឱសថ **ចុចទីនេះ។**
**៤. ត្រឹមត្រូវ.** ចូរអានបន្ថែមពីភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ក្នុងវិស័យកសិកម្ម និងការចិញ្ចឹមសត្វ **ចុចទីនេះ។**
**៥. ត្រឹមត្រូវ.** បាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក អាចចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន តាមរយៈការប៉ះពាល់ដោយផ្ទាល់ជាមួយមនុស្សដែលមានផ្ទុកបាក់តេរីទាំងនោះ។ រៀនបន្ថែមសូម **ចុចទីនេះ។**
**៦. ត្រឹមត្រូវ.** ដើម្បីអានបន្ថែមពីសុវត្ថិភាពអាហារ និងការបង្ការ **ចុចទីនេះ។**
**៧. ត្រឹមត្រូវ.** ចូរអាន **ទីនេះ** ដើម្បីឱ្យកាន់តែយល់ពីអត្ថប្រយោជន៍របស់ការបញ្ឈប់ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក។

បង្កើនចំណេះដឹងរបស់អ្នកអំពីឱសថអង់ទីប៊ីយោទិក ដែលអ្នកកំពុងតែលេប ដើម្បីឱ្យដឹងថា តើមេរោគអ្វីដែល



ត្រូវស្លាប់ដោយសារឱសថនេះ ឥទ្ធិពលបន្ទាប់បន្សំរបស់ឱសថ និងសក្ដានុពលនៃផលប៉ះពាល់របស់វាទៅលើសង្គម។ ភាពស៊ាំរបស់ឱសថអង់ទីប៊ីយោទិក មិនត្រឹមតែប៉ះពាល់ដល់ខ្លួនអ្នក មិត្តភក្តិ ឬគ្រួសាររបស់អ្នកនោះទេ ប៉ុន្តែវាប៉ះពាល់យ៉ាងធ្ងន់ទៅលើបរិស្ថានជុំវិញ និងមនុស្សគ្រប់គ្នានៅលើពិភពលោកទាំងមូលផងដែរ។

**ពាក្យទាក់ទង៖** ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ការបង្ករោគដោយមេរោគស៊ាំឱសថ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត ការជ្រើសរើសឱសថអង់ទីប៊ីយោទិកត្រឹមត្រូវ (antibiotic stewardship)

## សេចក្ដីយោង


[១] WHO (2015). "Antibiotic Resistance: Multi-country public awareness survey" (online ed.). *WHO*. ISBN 978 92 4 150981 7

[២] Ramsey L (2017). "A growing threat could kill 10 million people a year by 2050." *Businessinder.com*

## ជំពូក២៖ ភាពស៊ាំ

### ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក (ភាពស៊ាំនឹងថ្នាំផ្សះ)

*(នាម)* លទ្ធភាពរបស់បាក់តេរីក្នុងការបញ្ឈប់ពីការសម្លាប់ ឬសកម្មភាពប្រឆាំងរបស់ឱសថអង់ទីប៊ីយោទិកមួយប្រភេទ (ឬច្រើនប្រភេទ) មកលើវា។

«ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងមិនត្រឹមត្រូវ អាចធ្វើឱ្យមានភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក។»

«ទោះបីជាការប្រើប្រាស់ត្រឹមត្រូវនិងតាមវេជ្ជបញ្ជាក៏ដោយ ក៏ឱសថអង់ទីប៊ីយោទិកនៅតែអាចធ្វើឱ្យបាក់តេរីវិវត្តទៅរកភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកបានដែរ។ ប៉ុន្តែ ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកមានការកើនឡើងជាលំដាប់នេះក៏ព្រោះតែការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកនៅពេលពុំចាំបាច់និងលើសកម្រិត។» [១]

## ពាក្យស្រដៀង

### ដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក

*(គុណនាម)* ដែលមានលទ្ធភាពក្នុងការបញ្ឈប់សកម្មភាពរបស់ឱសថអង់ទីប៊ីយោទិកប្រឆាំង ឬសម្លាប់ពួកវា។



«ការបង្ករោគដោយបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិកនាពេលថ្មីៗនេះ បានឆក់យកជីវិតមនុស្សប្រមាណ ៥០ ០០០នាក់ជារៀងរាល់ឆ្នាំ ដូចជា បណ្តាប្រទេសនៅអឺរ៉ុប ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិក ។» [១]

## ចំណុចគួរស្វែងយល់

### តើអ្វីជាមូលហេតុនាំឱ្យមានភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក?

ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកខ្លះកើតឡើងពីធម្មជាតិ។ នេះក៏ព្រោះតែឱសថអង់ទីប៊ីយោទិកមួយចំនួនដូចជាឱសថប៉េនីស៊ីលីន (Penicillin) ត្រូវបង្កើតចេញពីពពួកផ្សិត ឬបាក់តេរីផ្សេងទៀត អាចត្រូវបានរកឃើញនៅក្នុងដី។ ដើម្បីរស់រានមានជីវិត ពួកមីក្រុប (រួមមាន៖ បាក់តេរី វីរុស ប៉ារ៉ាស៊ីត និង ពពួកផ្សិត) អាចធ្វើការសម្របខ្លួនបន្តិចម្តងៗ និងប្រែក្លាយទៅជាស៊ាំនឹងឱសថអង់ទីប៊ីយោទិក។ ជាធម្មតាសារធាតុឱសថអង់ទីប៊ីយោទិកនៅក្នុងបរិស្ថានមានកម្រិតទាបបំផុត ហើយការបង្ករោគដោយបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក គឺកើតមានដោយកម្រនៅទស្សវត្សឆ្នាំ១៩៣០ (ភ្លាមៗបន្ទាប់ពីការបង្កើតឱសថប៉េនីស៊ីលីន (Penicillin))។

ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងមិនត្រឹមត្រូវ បានកំពុងធ្វើឱ្យមានការកើនឡើងនូវអត្រានៃភាពស៊ាំនឹងឱសថដែលកំពុងវិវត្ត និងរាតត្បាតពាសពេញពិភពលោក។ តាមការប៉ាន់ស្មាន ឱសថអង់ទីប៊ីយោទិកប្រហែល ២០០ ០០០ ទៅ ២៥០ ០០០ តោន ត្រូវបានផលិត និងប្រើប្រាស់ទូទាំងពិភពលោករៀងរាល់ឆ្នាំ។ [១] [២] ប្រហែល ៧០% នៃឱសថអង់ទីប៊ីយោទិកត្រូវបានប្រើប្រាស់លើសត្វ និង៣០% លើមនុស្ស។

ភាគច្រើននៃឱសថអង់ទីប៊ីយោទិកដែលប្រើលើមនុស្ស និងសត្វ  គឺបញ្ចេញចោលមកវិញតាមទឹកនោម និងលាមក ហើយហូរចូលទៅក្នុងប្រព័ន្ធទឹកស្អុយ និងប៉ះពាល់ដល់បរិស្ថាន។ បន្ទាប់ពីប៉ះពាល់នឹងសារធាតុឱសថអង់ទីប៊ីយោទិក   បាក់តេរីដែលរស់នៅលើខ្លួនមនុស្ស និងសត្វអាចវិវត្តទៅជាស៊ាំនឹងឱសថអង់ទីប៊ីយោទិក ហើយបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិកទាំងនោះនឹងអាចចម្លងទៅមនុស្សដទៃទៀត និងទៅបរិស្ថាន[២] [៣]។

អ្នកដែលឈឺដោយសារការបង្ករោគដោយបាក់តេរី គឺត្រូវតែព្យាបាលដោយឱសថអង់ទីប៊ីយោទិក ប៉ុន្តែបើមិនបង្ករោគដោយបាក់តេរី មិនគួរប្រើឱសថអង់ទីប៊ីយោទិកនោះទេ។  លោក អេឡិចសេនឌឺ ហ្វ្លេមីង (Alexander Fleming) ដែលជាអ្នករកឃើញឱសថប៉េនីស៊ីលីន (Penicillin) បានធ្វើការទស្សន៍ទាយ ពីបញ្ហានៃភាពស៊ាំនឹងឱសថអង់ទីប៊ី-យោទិកតាំងពីដំបូងមកថា «**បុគ្គលដែលប្រើប្រាស់ឱសថប៉េនីស៊ីលីន** (Penicillin) **ដើម្បីព្យាបាលជំងឺ ដោយខ្វះការពិចារណា គឺជាការទទួលខុសត្រូវខាងសីលធម៌ចំពោះការស្លាប់របស់មនុស្ស ដែលរងគ្រោះដោយសារការបង្ករោគដោយមេរោគស៊ាំនឹងឱសថប៉េនីស៊ីលីន** (Penicillin)» ។

សព្វថ្ងៃនេះ ឱសថប៉េនីស៊ីលីន (Penicillin) ត្រូវបានប្រើប្រាស់តិចតួចបំផុត ដើម្បីព្យាបាលការបង្ករោគលើមនុស្សនិងសត្វ ពីព្រោះមេរោគដែលបង្កជំងឺញឹកញាប់គឺមានភាពស៊ាំទៅនឹងឱសថប៉េនីស៊ីលីន (Penicillin) រួចហើយ។ ឱសថអង់ទីប៊ីយោទិកជាច្រើនប្រភេទត្រូវបានប្រើប្រាស់ជំនួសឱសថប៉េនីស៊ីលីន (Penicillin)។ តាមការប៉ាន់ស្មាន ក្នុងមួយឆ្នាំៗ មានមនុស្សស្លាប់ប្រមាណ ៧០០ ០០០នាក់ ដោយសារមេរោគស៊ាំឱសថអង់ទីប៊ីយោទិក តួលេខនេះអាចនឹងមានការកើនឡើងដល់ ១០ ០០០ ០០០នាក់ គិតត្រឹមឆ្នាំ ២០៥០។ [២] យើងពុំទាន់ឃើញមានឱសថអង់-ទីប៊ីយោទិកក្រុមថ្មីសម្រាប់ទស្សវត្សនេះនៅឡើយទេ។

«យើងត្រូវការយុទ្ធនាក្នុងការលើកកម្ពស់ការយល់ដឹងជាសកល ដើម្បីអប់រំអំពីបញ្ហាស៊ាំនឹងឱសថ។ ខ្ញុំគិតថា វាជាបញ្ហាអាទិភាពមួយ។» [១]

តើអ្នកកំពុងប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវដែរឬទេ? សូមស្វែងរកព័ត៌មានបន្ថែមទាក់ទងនឹង «ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ» ។

**ពាក្យទាក់ទង៖** ឱសថអង់ទីប៊ីយោទិក បាក់តេរី ឱសថប៉េនីស៊ីលីន ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ

## សេចក្តីយោង


១ O'Niell J. (2016). "Tackling Drug-Resistant Infections Globally: Final Report and Recommendations.- The review on Antimicrobial Resistance." *amr-review.org*

២ Sarmah A.K., Meyer M.T., and Boxall A.B.A. (2006). "A global perspective on the use, sales, exposure pathways, occurrence, fate and effects of veterinary antibiotics (VAs) in the environment." *Science direct Chemosphere.* 65(5); 725-759. doi: 10.1016/j.chemophere.2006.03.026

៣ Van Boeckel T.P., Brower C., Gilbert A., Grenfell B.T., et al. (2015). "Global trends in antimicrobial use in food animals." *PNAS.* 112(18); 5649-5654. doi: 10.1073/pnas.1503141112


## ការបង្ករោគដោយមេរោគស៊ាំឱសថ (DRI)

*(នាម)* គឺជាការបង្ករោគដោយមេរោគដែលស៊ាំនឹងឱសថប្រឆាំងមេរោគ។

«ការបង្ករោគដោយមេរោគស៊ាំឱសថ គឺបណ្តាលមកពីមូលហេតុច្រើនយ៉ាង ដូចជាការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត ឬប្រើពេលមិនចាំបា

«ការបង្ករោគដោយមេរោគស៊ាំឱសថនៅក្នុងមន្ទីរ

### ចំណុចគួរស្វែងយល់

### មិនមែនរាងកាយរបស់អ្នកទេ គឺមេរោគ (bug) ដែលវិវត្តទៅជាស៊ាំនឹងឱសថអង់ទីប៊ីយោទិក

ចំពោះការស៊ាំនឹងឱសថអង់ទីប៊ីយោទិក រាងកាយរបស់អ្នកមិនបានវិវត្តទៅជាស៊ាំនឹងឱសថអង់ទីប៊ីយោទិកនោះទេ គឺបាក់តេរីទេដែលវិវត្តទៅជាស៊ាំនឹងឱសថអង់ទីប៊ីយោទិក ដោយសារបំរែបំរួលហ្សែនរបស់វា។ ជាទូទៅគោលដៅរបស់ឱសថអង់ទីប៊ីយោទិកគឺបាក់តេរី។ វាសម្លាប់ ឬបន្សាបសកម្មភាពបាក់តេរី និងជួយអ្នកដើម្បីទប់ទល់នឹងការបង្ករោគរបស់ពួកវា។

ប្រសិនបើអ្នកមានការបង្ករោគដោយបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក នោះឱសថអង់ទីប៊ីយោទិកដែលប្រើជាទូទៅ ដើម្បីប្រឆាំងនឹងបាក់តេរី នឹងមិនមានប្រសិទ្ធភាពទៀតទេ។ ឱសថអង់ទីប៊ីយោទិកដែលពិបាក

រកនៅលើទីផ្សារឬឱសថជំនាន់ក្រោយនឹងត្រូវប្រើ ក្នុងករណីខ្លះទៀតឱសថអង់ទីប៊ីយោទិកដែលមានសក្ដានុពលអាចនឹងអស់ពីស្តុក។ លើសពីនេះទៅទៀត បាក់តេរីដែលស៊ាំឱសថអង់ទីប៊ីយោទិកស្ថិតក្នុងរាងកាយរបស់អ្នក អាចឆ្លងទៅសាច់ញាតិ និងមនុស្សដទៃទៀតក្នុងសង្គម។ មូលហេតុដែលធ្វើឱ្យមានភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកមានច្រើនយ៉ាង ប៉ុន្តែមូលហេតុចម្បងគឺការប្រើប្រាស់លើសកម្រិត និងមិនត្រឹមត្រូវ។ ជាទូទៅ អ្នកជំងឺទទួលបានឱសថអង់ទីប៊ីយោទិកពី  វេជ្ជបណ្ឌិត ទិញដោយគ្មានវេជ្ជបញ្ជា ឬករណីខ្លះទៀតគឺប្រើប្រាស់មិនត្រឹមត្រូវ (ឧទាហរណ៍៖ ប្រើឱសថអង់ទីប៊ីយោទិកពេលមានជំងឺបង្ករោគដោយវីរុស)។

ឱសថអង់ទីប៊ីយោទិក ក៏ត្រូវបានកំពុងប្រើប្រាស់នៅក្នុងកសិដ្ឋាន និងសាយភាយទៅក្នុងបរិស្ថាន។ ការគ្រប់គ្រងការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកពុំបានល្អ និងការវិវត្តនៃការបង្ករោគដោយមេរោគស៊ាំនឹងឱសថ អាចនឹងបន្សល់ឱ្យយើងនូវភាពពុំមានឱសថសម្រាប់ព្យាបាលនាពេលអនាគត។[១]

បើអ្នកមានចំណាប់អារម្មណ៍ និងចង់អានបន្ថែម នូវអ្វីដែលអ្នកអាចធ្វើបាន សូម ចុចត្រង់នេះ



**ពាក្យទាក់ទង៖** ឱសថព្យាបាលមេរោគរបេង ឱសថព្យាបាលមេរោគគ្រុនចាញ់

## សេចក្ដីយោង

[១] WHO (2015). “Worldwide country situation analysis: response to antimicrobial resistance. *WHO*

**មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (Superbug)**
*(នាម)* ភាពធន់របស់បាក់តេរី ដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ

«ការគំរាមកំហែងរបស់មេរោគស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug) គឺបណ្ដាលមកពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិតក្នុងវិស័យវេជ្ជសាស្ត្រ។»

«ដើម្បីការពារអ្នកពីការបង្ករោគដោយមេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug) សូមលាងដៃរបស់អ្នក។»

« Superbug អាចបណ្ដាលឱ្យអ្នកស្លាប់បាន ទោះបីជាអ្នកបានធ្វើតាមទំរង់ការវេជ្ជសាស្ត្រទូទៅធម្មតាក៏ដោយ។» [១]

«ប្រសិនបើយើងមិនធ្វើអ្វីពីឥឡូវនេះទេ មេរោគស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbugs) នឹងសម្លាប់យើងមុនការប្រែប្រួលអាកាសធាតុ។» [២]

## ចំណុចគួរស្វែងយល់

### កំណើននៃមេរោគស៊ាំឱសថ (superbugs)

ដោយផ្អែកលើប្រព័ន្ធផ្សព្វផ្សាយ ពាក្យ «មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug)» នេះ ត្រូវបានប្រើប្រាស់កាន់តែច្រើន ដើម្បីនិយាយអំពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ពាក្យ «មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug)» បានមានវត្តមាននៅលើសារព័ត៌មានដ៏មានប្រជាប្រិយមួយ ក្រោយឆ្នាំ១៩៧០ ដែលបានពណ៌នាយ៉ាងស៊ីជំរៅពីការពុលអាហារដោយសារពួកមីក្រុប។[៣] បន្ទាប់មកពាក្យនេះបានវិវត្តទៅជាពាក្យប្រើដើម្បីបញ្ជាក់ពីបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ និងពិបាកព្យាបាល។

ប្រព័ន្ធផ្សព្វផ្សាយអាចឆ្លុះបញ្ចាំងពីទស្សនៈ និងអាកប្បកិរិយារបស់សាធារណជនទូទៅ។[៤] ឆ្នាំ១៩៩៦ ស្ថានីយ៍ទូរទស្សន៍ BBC’s Panorama របស់ចក្រភពអង់គ្លេស បាន

បង្កើតកម្មវិធីមួយស្តីអំពីភាពស៊ាំនឹងឱសថដែលឱ្យឈ្មោះថា «មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (Superbugs)» ដែលផ្តោតលើការកើនឡើង នៃបាក់តេរីស៊ាំជាមួយនឹងឱសថ Vanconmycin ដែលមានឈ្មោះថា Enterococcus។ ប្រធានបទ «មេរោគស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug)» នៅលើប្រព័ន្ធផ្សព្វផ្សាយបានក្លាយទៅជាប្រធានបទដែលត្រូវបានតាមដានយ៉ាងយកចិត្តទុកដាក់បំផុត។

ក្រោយមកទៀត ក្នុងឆ្នាំ២០០៥ ប្រធានបទ «មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug)» គឺផ្តោតលើមេរោគ MRSA វិញ។ វាក្លាយទៅជាប្រធានបទដ៏ចម្បងសម្រាប់ការប្រកួតប្រជែងរកសន្លឹកឆ្នោតរបស់គណបក្ស២ អំឡុងពេលបោះឆ្នោតជាតិ។ ទោះបីជាមានសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយសង្គមមួយចំនួនបានយកប្រធានបទនេះមកបកស្រាយក្នុងកម្មវិធីរបស់ពួកគេ តែមានអ្នកអានមួយចំនួនបានយល់ច្រឡំពីបញ្ហា និងសកម្មភាពអាទិភាពនៅពេលនោះដែរ។

បច្ចុប្បន្ននេះ បញ្ហាចម្បងដែលមនុស្សមានការព្រួយបារម្ភពី «មេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug)» គឺត្រូវដឹងពីវិធីប្រយុទ្ធប្រឆាំងនឹងបញ្ហានេះ។

បើអ្នកចង់ស្វែងយល់បន្ថែមអំពីរបៀបនៃការប្រយុទ្ធប្រឆាំងនឹងបញ្ហាមេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug) ឬ ការស៊ាំឱសថច្រើនមុខ សូមអានបន្ថែមត្រង់ចំណុច «ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ» «ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក» «antibiotic footprint» និង «ការជ្រើសរើសឱសថអង់ទីប៊ីយោទិកត្រឹមត្រូវ (antibiotic stewardship)»។

## សេចក្តីយោង


[១] Nuki P. & Gulland A. (2018). "Superbugs could render even the most routine procedures deadly, warns chief medical officer." *The Telegraph.*

[២] Armstrong S. (2017). "If we don't act now, superbugs will kill us before climate change does." *wired.co.uk.*

[៣] Mosher D. (2012). "What is a Superbug?" *livescience.com*

[៤] Reynolds L.A. and Tansey E.M. (2006). "Superbugs and Superdrugs: A History of MRSA." *The Wellcome Trust Centre for the History of Medicine at UCL.*

## ដែលស៊ាំឱសថច្រើនប្រភេទ (MDR)

*(គុណនាម)* មានសមត្ថភាពក្នុងការបញ្ឈប់សកម្មភាពបំផ្លាញរបស់ឱសថប្រឆាំងនឹងមេរោគ (រួមមាន៖ ឱសថអង់ទីប៊ីយោទិក ឱសថប្រឆាំងពួកវីរុស ឱសថប្រឆាំងពួកផ្សិត និង ឱសថប្រឆាំងពួកប៉ារ៉ាស៊ីត)។

> «បាក់តេរីដែលស៊ាំនឹងឱសថច្រើនមុខគឺបង្កគ្រោះថ្នាក់ ហើយមានការគំរាមកំហែងលើសុខសាធារណៈ ដោយសារពួកវាមានភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ។»

> «របៀបនៃការព្យាបាលថ្មី ត្រូវប្រើរយៈពេលពី ៩ ទៅ ១១ខែ ដើម្បីព្យាបាលមេរោគរបេងស៊ាំឱសថច្រើនប្រភេទ(MDR)។»

## ពាក្យស្រដៀង

**ភាពស៊ាំនឹងឱសថច្រើនមុខ** (MDR)

*(នាម)* សមត្ថភាពរបស់អតិសុខុមកាយ ក្នុងការបញ្ឈប់សកម្មភាពរបស់ឱសថប្រឆាំងនឹងមេរោគមកលើពួកវា។

> «ប៉ារ៉ាស៊ីតជំងឺគ្រុនចាញ់ អាចវិវត្តខ្លួនឱ្យស៊ាំនឹងឱសថច្រើនប្រភេទ ទៅនឹងការព្យាបាលជំងឺដោយឱសថខ្សែទី១យ៉ាងលឿន ប្រសិនបើអ្នកជំងឺមិន

> «ការកើនឡើងនៃការឆ្លងរាលដាលនិងភាពស៊ាំឱសថច្រើនមុខនៃអតិសុខុមកាយ ធ្វើឱ្យស្ថានភាពកាន់តែធ្ងន់ឡើង។»

**ដែលស៊ាំឱសថស្ទើរគ្រប់មុខ** (XDR)

*(គុណនាម)* ដែលជាសមត្ថភាពនៃអតិសុខុមកាយក្នុងការបញ្ឈប់សកម្មភាពរបស់ឱសថប្រឆាំងនឹងមេរោគភាគច្រើន មកលើវា។ នៅសល់តែឱសថប្រឆាំងមេរោគមួយឬពីរក្រុមប៉ុណ្ណោះដែលអាចនៅមានប្រសិទ្ធភាពមកលើវា។

**ភាពស៊ាំឱសថគ្រប់មុខ** (PDR)

*(គុណនាម)* ដែលជាសមត្ថភាពនៃអតិសុខុមកាយក្នុងការបញ្ឈប់សកម្មភាពរបស់ឱសថប្រឆាំងមេរោគគ្រប់ប្រភេទមកលើវា។ វាស៊ាំនឹងឱសថប្រឆាំងមេរោគគ្រប់ប្រភេទ។

## ចំណុចគួរស្វែងយល់

## ភាពស៊ាំនឹងឱសថច្រើនមុខ គឺជាបញ្ហាដែលបង្កឡើងដោយមនុស្ស

ស្ទើរគ្រប់មូលហេតុនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគច្រើនមុខគឺបង្កឡើងដោយមនុស្ស។ ឧទាហរណ៍៖ មេរោគរបេងដែលស៊ាំនឹងឱសថច្រើនមុខ (MDR TB) គឺកើតឡើងដោយការព្យាបាលដោយឱសថព្យាបាលរបេងមិនគ្រប់កម្រិត ឬមិនត្រឹមត្រូវ។[១] ដោយសាររយៈពេលព្យាបាលយូរ និងផលរំខាននៃឱសថ បានធ្វើឱ្យអ្នកជំងឺមិនបានអនុវត្តអនុសាសន៍នៃការព្យាបាល។ នៅពេលអ្នកជំងឺមានអារម្មណ៍ប្រសើរឡើង អ្នកជំងឺបានឈប់លេបឱសថ។ បាក់តេរីបង្កជំងឺរបេង នៅពុំទាន់បានត្រូវបានសម្លាប់ឱ្យអស់ពីក្នុងខ្លួនរបស់អ្នកជំងឺ នឹងវិវត្តខ្លួនឱ្យស៊ាំនឹងឱសថព្យាបាលជំងឺរបេងខ្សែទី១ ដែលអ្នកជំងឺបានប្រើរួច។ នៅពេលអ្នកជំងឺធ្លាក់ខ្លួនឈឺម្តងទៀត វាមិនគ្រាន់តែស៊ាំនឹងឱសថព្យាបាលជំងឺរបេងខ្សែទី១ប៉ុណ្ណោះទេ វាថែមទាំងមានលទ្ធភាពធ្វើការចម្លងយ៉ាងខ្លាំងក្លា និងអាចធ្វើឱ្យស្លាប់បានទៀតផង។

CRE (Carbapenem-resistant Enterobacteriaceae) សំដៅលើគ្រួសាររបស់បាក់តេរីដែលស៊ាំនឹងឱសថច្រើនមុខ រួមទាំងឱសថកាបាពៀណែម (Carbapenem)។ ពួកវាតែងធ្វើការវិវត្តខ្លួន ដូចនេះឱសថអង់ទីប៊ីយោទិកស្ទើរគ្រប់ប្រភេទទាំងអស់មិនអាចសម្លាប់វាបានទេ ហេតុនេះហើយវាត្រូវបានចាត់ចូលក្នុងក្រុមមេរោគដែលមានភាពស៊ាំនឹងឱសថច្រើនមុខ (superbugs)។ ឱសថកូលីស្ទីន (Colistin) គឺជាឱសថអង់ទីប៊ីយោទិកជម្រើសចុងក្រោយសម្រាប់ការព្យាបាល CRE និងការបង្ករោគដោយបាក់តេរី Gram **ក្រាម** អវិជ្ជមាន(-)ដែលស៊ាំនឹងឱសថច្រើនមុខ។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិតនៅក្នុងមន្ទីរពេទ្យនិងក្នុងសហគមន៍បាន ជម្រុញដល់ការលូតលាស់របស់បាក់តេរីដូច CRE ជាដើម។ បាក់តេរីដែលស៊ាំឱសថទាំងនេះរួមទាំង CRE អាចឆ្លងរាលដាលនិងបង្ករោគដល់មនុស្សជាច្រើន។ អ្នកគឺជាបុគ្គលដែលមានហានិភ័យខ្ពស់ពីការបង្ករោគដោយ CRE ប្រសិនបើអ្នកកំពុងស្នាក់នៅក្នុងមន្ទីរពេទ្យ ឬសម្រាកព្យាបាលរយៈពេលយូរ ឬបានប្រើប្រាស់ឱសថអង់ទីប៊ីយោទិក។ ជារឿយៗ ការបង្ករោគដោយ CRE បណ្តាលឱ្យស្លាប់បាន។

មេរោគ Acinetobacter ដែលស៊ាំឱសថច្រើនមុខ (MDR) គឺត្រូវបានស្គាល់ថាជាមេរោគដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិកដ៏សំខាន់ នៅក្នុងវិស័យសុខាភិបាល។ ជាប្រវត្តិសាស្ត្រ ក្រុមឱសថ Carbapenem មានប្រសិទ្ធភាពល្អបំផុតសម្រាប់ការព្យាបាលការបង្ករោគដោយ Acinetobacter ដែលស៊ាំឱសថ

ច្រើនមុខ។ ទោះបីជាយ៉ាងក៏ដោយ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិតនិងមិនត្រឹមត្រូវ រួមទាំង Carbapenems ផងនោះ ធ្វើឱ្យ Acinetobacter វិវត្តទៅជាស៊ាំឱសថ Carbapenems និងឆ្លងរាលដាល។ មេរោគ Acinetobacter ដែលស៊ាំឱសថច្រើនមុខ (MDR) អាចបណ្តាលឱ្យមានបង្ករោគធ្ងន់ និងពិបាកក្នុងការព្យាបាល។

ដើម្បីដោះស្រាយបញ្ហាភាពស៊ាំឱសថច្រើនមុខ (MDR) មន្ទីរពេទ្យត្រូវតែអនុវត្តនូវការសម្អាត ត្រូវប្រាកដថាមនុស្សគ្រប់គ្នាលាងដៃមុនពេលនិងក្រោយពេលប៉ះអ្នកជំងឺនិងបរិវេណជុំវិញអ្នកជំងឺ។ មន្ទីរពេទ្យត្រូវអនុវត្តនិងជម្រុញឱ្យមានកម្មវិធី ការជ្រើសរើសឱសថអង់ទីប៊ីយោទិកត្រឹមត្រូវ (stewardship program) ។ ប្រជាជននៅក្នុងសហគមន៍ ត្រូវតែលាងដៃ រក្សាអនាម័យខ្លួនប្រាណ និងបញ្ឈប់ប្រើប្រាស់ឱសថប្រឆាំងមេរោគលើសកម្រិតនិងមិនត្រឹមត្រូវ។

បើអ្នកចង់ស្វែងយល់បន្ថែមអំពីរបៀបនៃការប្រយុទ្ធប្រឆាំងនឹងបញ្ហាមេរោគស៊ាំឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ (superbug) ឬការស៊ាំឱសថច្រើនមុខ សូមអានបន្ថែមត្រង់ចំណុច «ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ» «ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក» «antibiotic footprint» និង «ការជ្រើសរើសឱសថអង់ទីប៊ីយោទិកត្រឹមត្រូវ»។

**ពាក្យទាក់ទង៖** ឱសថអង់ទីប៊ីយោទិក ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ការបង្ករោគដោយមេរោគស៊ាំឱសថ

## សេចក្តីយោង

[១] Huber C. (2014). "The causes of multi-drug resistant tuberculosis." *The Borgen Project*

## ជំពូក៣៖ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក

### ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគ

*(នាម)* ការអនុវត្តនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់ការពារកុំឱ្យឆ្លងជំងឺ ឬការបង្ករោគ។

> “ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគ ធម្មតាប្រើនៅពេលវះកាត់ធំដែលអាចមានការប្រឈមខ្ពស់នឹងការបង្ករោគដោយសារតែបាក់តេរីចូលទៅក្នុងរាងកាយ ជាពិសេសចូលតាមរបួស។”

## ពាក្យស្រដៀង

**ឱសថអង់ទីប៊ីយោទិកសម្រាប់ការពារកុំឱ្យឆ្លងជំងឺ** (MDR)

*(នាម)* ការអនុវត្តនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់ការពារកុំឱ្យឆ្លងជំងឺ ឬការបង្ករោគ។

## ចំណុចគួរស្វែងយល់

### ហេតុអ្វីឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគត្រូវបានប្រើប្រាស់លើមនុស្ស និងសត្វ?

កាលពីមុន ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគត្រូវបានប្រើប្រាស់លើមនុស្ស និងសត្វយ៉ាងទូលំទូលាយ។ បន្ទាប់ពីដាក់ឱ្យប្រើប្រាស់ឱសថប៉េនីស៊ីលីន (Penicillin) ក្នុងឆ្នាំ១៩២៨ វាបានបង្ហាញឱ្យឃើញថា ការប្រើប្រាស់  ឱសថអង់ទីប៊ីយោទិក អាចកាត់បន្ថយអត្រា នៃការបង្ករោគជាច្រើន នៅលើមុខរបួសវះកាត់។[១] កាលពីមុនឱសថសម្រាប់ បង្ការការបង្ករោគត្រូវបានចេញវេជ្ជបញ្ជាដោយខ្វះរបៀបរៀបរយ។ នៅពេលដែលការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកកើនឡើង បញ្ហាភាពស៊ាំទៅនឹងឱសថអង់ទីប៊ីយោទិក និងការចម្លងរោគនៅក្នុងមន្ទីរពេទ្យដែលបណ្ដាលមកពីបាក់តេរីទាំងអស់នោះក៏បានលេចឡើងជាបញ្ហា។ នៅក្នុងផលិតផលបសុសត្វ កសិករប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគដើម្បីការពារសត្វរបស់ពួកគេពីការស្លាប់ ហើយលើសពីនេះទៅទៀតក្នុងប្រទេសខ្លះប្រើចំពោះសត្វដែលមានសុខភាពល្អដើម្បីពន្លឿនការលូតលាស់ផងដែរ។

កាលពី១០ឆ្នាំមុន ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគ មិនត្រូវបានប្រើប្រាស់ច្រើនដូចសព្វថ្ងៃនេះទេ។ នេះគឺដោយសារតែការកើនឡើងនៃភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក  ការផ្លាស់ប្ដូរនៃបាក់តេរីដែលបង្ករោគ និងការវិវត្តនៃបច្ចេកវិទ្យាដែលអាចរកឃើញការបង្ករោគដោយសារបាក់តេរី។

នៅតែឃើញមាន គោលការណ៍ណែនាំផ្នែកវេជ្ជសាស្ត្របន្តណែនាំឱ្យមានការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក មុនពេលធ្វើការវះកាត់ធំៗដែលមានការប្រឈមខ្ពស់នឹងការ

បង្ករោគពីបាក់តេរី។ ប៉ុន្តែ រយៈពេលនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ដើម្បីបង្ការការបង្ករោគត្រូវបានកាត់បន្ថយយ៉ាងខ្លាំង ហើយមិនណែនាំឱ្យប្រើឱសថអង់ទីប៊ីយោទិក ក្នុងរយៈពេលវែង បន្ទាប់ពីធ្វើការវះកាត់រួចនោះទេ។ ក្នុងនោះដែរ បានឈប់ណែនាំឱ្យប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ដើម្បីបង្ការការបង្ករោគលើទំរង់ការព្យាបាលធ្មេញ លុះត្រាតែអ្នកជំងឺមានជំងឺប្រើសបេះដូងសិប្បនិម្មិត ឬជំងឺខូចប្រើសបេះដូងជាដើម។

នៅឆ្នាំ២០១៧ អង្គការសុខភាពពិភពលោកបានផ្តល់អនុសាសន៍យ៉ាងតឹងរឹង លើការកាត់បន្ថយទូទៅនូវការប្រើប្រាស់ក្រុមឱសថអង់ទីប៊ីយោទិក ដែលមានសារៈសំខាន់ក្នុងផ្នែកវេជ្ជសាស្ត្រគ្រប់ប្រភេទ នៅក្នុងផលិតផលសាច់សត្វ ដោយរាប់បញ្ចូលទាំងការរឹតត្បិតការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកទាំងនេះ សម្រាប់ពន្លឿនការលូតលាស់ និងការបង្ការការឆ្លងជំងឺដោយគ្មានការធ្វើរោគវិនិច្ឆ័យ។[២] សត្វដែលមានសុខភាពល្អ គួរទទួលបាននូវឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគ ប្រសិនបើសត្វណាមួយនៅក្នុងក្រោលតែមួយ ហ្វូង ឬក្រុមសត្វដូចគ្នា ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានការបង្ករោគដោយបាក់តេរី។

វាគួរឱ្យកត់សំគាល់ដែលថា បណ្តាប្រទេសជាច្រើនកំពុងលើកកម្ពស់យុទ្ធនាការ ដើម្បីបញ្ឈប់ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក សម្រាប់ពន្លឿនការលូតលាស់របស់សត្វ ដោយកសិករអាចនឹងងាកមកប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគជំនួសវិញ។ បន្ទាប់មក បរិមាណនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសរុបនៅក្នុងផ្នែកបសុសត្វ អាចនឹងមានស្ថេរភាព ឬក៏មានការកើនឡើងជាងមុន។[៣] ដូច្នេះហើយ វាមានសារៈសំខាន់ណាស់ក្នុងការអនុវត្តតាមការណែនាំរបស់អង្គការសុខភាពពិភពលោក ដើម្បីរឹតបន្តឹងការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់បង្ការការបង្ករោគដោយគ្មានការធ្វើរោគវិនិច្ឆ័យ។

ជម្រើសផ្សេងទៀតដើម្បីជៀសពីការប្រើឱសថអង់ទីប៊ីយោទិកសម្រាប់ការបង្ការការបង្ករោគលើសត្វ រួមមានការថែរក្សាអនាម័យឱ្យបានល្អ ការចាក់វ៉ាក់សាំងបង្ការ ការផ្លាស់ប្តូរជំរក និងបែបបទនៃការចិញ្ចឹមសត្វ។

**ពាក្យទាក់ទង៖** ឱសថអង់ទីប៊ីយោទិក ចំណីសត្វដែលមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក

## សេចក្តីយោង

[1] Westerman E.L. (1984). “Antibiotic prophylaxis in surgery: Historical background, rationale, and relationship to prospective payment.” *AJIC.* 12(6); 339-343. doi: 10.1016/0196-6553(84)90007-5

[2] WHO (2017). “Stop using antibiotics in heathy animals to prevent the spread of antibiotic resistance”. *WHO.*

[3] Mevius D., Heederik D. (2014). “Reduction of antibiotic use in animals “let’s go Dutch.” *J. Verbr.Lebensm.* 2014(9); 177-181. doi: 10.1007/s00003-014-0874-z

## ដែលទិញ ឬលក់ដោយគ្មានវេជ្ជបញ្ជា (OTC)

*(គុណនាម)* ដែលទិញ ឬលក់វត្ថុដោយគ្មានការត្រួតពិនិត្យ។

“ការទិញ ឬលក់ឱសថដោយគ្មានវេជ្ជបញ្ជា គឺត្រូវបានគេស្គាល់ថាជាឱសថដែលមិនត្រូវការវេជ្ជបញ្ជា។ ពាក្យទាំងនោះសំដៅទៅលើ ឱសថទាំងឡាយណាដែលអ្នកអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា។”

“នៅប្រទេសអភិវឌ្ឍ អ្នកមិនអាចទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជាបានឡើយ។ ដោយឡែក នៅប្រទេសកំពុងអភិវឌ្ឍជាច្រើនទៀត អ្នកអាចទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជាបាននៅតាម ឱសថស្ថាន ឬកន្លែងលក់គ្រឿងទេស។”

“ការដែលអាចទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជា ប្រហែលជាយន្តការមួយដ៏សំខាន់សម្រាប់មនុស្សដែលត្រូវការវា។ ប៉ុន្តែការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជាច្រើនពេកចំពោះអ្នកមិនត្រូវការវា គឺជាកង្វល់ដ៏ធំមួយ។”

## ចំណុចគួរស្វែងយល់

## គ្រោះថ្នាក់នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជា

ការប្រើប្រាស់ឱសថដោយខ្លួនឯងអាចបង្កឱ្យមានគ្រោះថ្នាក់ដល់អ្នកដែលមិនដឹងពីផលរំខានរបស់វា និងផលប៉ះពាល់ដែល បណ្តាលមកពីកាប្រើប្រាស់លើសកម្រិត។ នៅបណ្តាប្រទេសជាច្រើន ឱសថដែលមិនចាំបាច់មានវេជ្ជបញ្ជាត្រូវបានជ្រើសរើស ត្រួតពិនិត្យដោយភ្នាក់ងារនិយ័តករ ដើម្បីធានាថា ពួកគេលេបដោយសុវត្ថិភាព និងមានប្រសិទ្ធភាព នៅពេលប្រើដោយគ្មានការថែទាំពីគ្រូពេទ្យ។ ឧទាហរណ៍  ឱសថប៉ារ៉ាសេតាមុល(Paracetamol) អាចទិញដោយមិនចាំបាច់មានវេជ្ជបញ្ជាបានទូទាំងពិភពលោក។ ទោះជាយ៉ាងណាក៏ដោយ ការប្រើឱសថប៉ារ៉ាសេតាមុល (Paracetamol) លើសកម្រិតអាចសម្លាប់យើងបាន ហើយ ប្រទេសមួយចំនួនក៏បានកំណត់ចំនួនគ្រាប់ឱសថដែលអាចលក់បានផងដែរ។

ឱសថអង់ទីប៊ីយោទិក ត្រូវបានលក់ដោយគ្មានវេជ្ជបញ្ជាស្ទើរគ្រប់ទីកន្លែងនៅពាសពេញពិភពលោក ហើយវាកំពុងជំរុញឱ្យមានបញ្ហាភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ដែលគ្មានវេជ្ជបញ្ជាភាគច្រើន គឺប្រើប្រាស់មិនត្រឹមត្រូវ ព្រោះវាត្រូវបានគេប្រើសម្រាប់ជំងឺដែលមិនមែនបង្កឡើងដោយបាក់តេរី។[១] ឱសថត្រូវបានចែកចាយដល់អ្នកជំងឺ ដោយមិនយល់ច្បាស់ថា តើអ្នកជំងឺប្រតិកម្មនឹងឱសថ ឬក៏អត់។  ជាទូទៅ រយៈពេលនៃការប្រើឱសថអង់ទីប៊ីយោទិក ខ្លីជាងរយៈពេលដែលវាគួរតែប្រើ ហើយកម្រិតប្រើប្រាស់របស់ឱសថអង់ទីប៊ីយោទិក ក៏តិចជាងកម្រិតស្តង់ដាផងដែរ។

ភាពងាយស្រួលក្នុងការទទួលបាននូវឱសថអង់ទីប៊ីយោទិកជាមួយការខ្វះចំណេះដឹងទាក់ទងនឹងឱសថអង់ទីប៊ីយោទិកបានរួមបញ្ចូលគ្នាបង្កើតជាវដ្តនៃការប្រើប្រាស់លើសកម្រិតដែលផ្តល់ផលអាក្រក់។ ការប្រើប្រាស់លើសកម្រិតបែបនេះបានជំរុញឱ្យមានភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ជាការពិតណាស់ បាក់តេរីដែលស៊ាំនឹងឱសថប្រឆាំងមេរោគជាទូទៅកើតនៅក្នុងសហគមន៍ដែលប្រើឱសថអង់ទីប៊ីយោទិកញឹកញាប់ដោយគ្មានវេជ្ជបញ្ជា។[១]

ការលក់ ឬទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជានៅតែមាន ភាគច្រើននៅក្នុងប្រទេសកំពុងអភិវឌ្ឍ ព្រោះវាមានសារៈសំខាន់ចំពោះអ្នកដែលត្រូវការឱសថអង់ទីប៊ីយោទិក ។ ប្រសិនបើ ឱសថអង់ទីប៊ីយោទិក ត្រូវបានគេឈប់ឱ្យលក់ដោយគ្មានវេជ្ជបញ្ជា វានៅតែមិនច្បាស់លាស់ចំពោះអ្នកបង្កើតច្បាប់ថា តើធនធានដែលត្រូវប្រើដើម្បី

រៀបចំប្រព័ន្ធចេញវេជ្ជបញ្ជា និងការលើកកម្ពស់ការទទួលបាននូវសេវាថែទាំសុខភាពឱ្យមានកម្រិតទាបជាង ការខាតបង់ដែលបណ្តាលមកពីការកើនឡើងនៃភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកនៅក្នុងប្រទេស។ លើសពីនេះទៅទៀត ទស្សនៈសាធារណជន ឥរិយាបថ និងការយល់ច្រឡំអំពីឱសថអង់ទីប៊ីយោទិក អាចរាំងស្ទះដល់ការផ្លាស់ប្តូរនេះ។

ប្រទេសម៉ាឡេស៊ី ជាប្រទេសកំពុងអភិវឌ្ឍមួយដែលហាមឃាត់ការលក់ ឬទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជា។[២] នៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងសារធាតុពុល នៃប្រទេសម៉ាឡេស៊ី ការទិញឱសថអង់ទីប៊ីយោទិក តម្រូវឱ្យមានវេជ្ជបញ្ជាពីគ្រូពេទ្យ។ ទោះជាយ៉ាងណាក៏ដោយ គេបានសង្កេតឃើញថានៅបណ្តាលប្រទេសមួយចំនួនមានច្បាប់ទប់ស្កាត់ការចែកចាយប្រើឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជា ប៉ុន្តែមិនត្រូវបានអនុវត្តនៅក្នុងសហគមន៍ទេ។

នៅប្រទេសម៉ាឡេស៊ី ទោះបីជាមានការទប់ស្កាត់ការលក់ ឬទិញឱសថអង់ទីប៊ីយោទិកដែលគ្មានវេជ្ជបញ្ជាក៏ដោយ ប៉ុន្តែអត្រានៃការផ្តល់ឱសថអង់ទីប៊ីយោទិកដោយមានវេជ្ជបញ្ជានៅតែមានកម្រិតខ្ពស់នៅក្នុងមន្ទីរពេទ្យរដ្ឋ និងឯកជន។ [២] នេះបានបង្ហាញឱ្យឃើញថា ជំហានបន្ទាប់ដើម្បីកាត់បន្ថយការប្រើឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ រួមមាន ការមិនលក់ ឬទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជា និងតម្រូវឱ្យមានការផ្តល់ឱសថអង់ទីប៊ីយោទិកត្រឹមត្រូវពីវេជ្ជបណ្ឌិតផងដែរ។

**ពាក្យទាក់ទង៖** ផ្លាស្មាយផម្មតា ការបង្ករោគ ជំងឺរាក ការពុលចំណីអាហារ

## សេចក្តីយោង


[1] Morgan D.J., Okeke. I.N. et al. (2011). “Non-prescription antimicrobial use worldwide: a systematic review.” *The Lancet Infectious Disease.* 11(9); 682-701. doi: 10.1016/S1473-3099(11)70054-8

[2] Rahman N.A.B., Teng C.L., and Sivasampu A. (2016). “Antibiotic prescribing in public and private practices: a cross-sectional study in primary care clinics in Malaysia.” *BMC infectious Disease.* 16(208). doi: 10.1186/s12879-016-1530-2

**ការប្រើប្រាស់ឱសថដែលសមស្រប (RDU)**

*(នាម)* សកម្មភាពនៃការប្រើប្រាស់ឱសថដែលត្រឹមត្រូវទៅតាមរោគវិនិច្ឆ័យរបស់អ្នកជំងឺដូចជា កម្រិតឱសថត្រឹមត្រូវ រយៈពេលនៃការផ្តល់ឱសថត្រឹមត្រូវ និងមានតម្លៃទាបដល់សហគមន៍។

> "ការប្រើប្រាស់ឱសថដែលសមស្របអាចជួយបុគ្គលគ្រប់រូបកាត់បន្ថយការចំណាយលើការប្រើប្រាស់ឱសថ និងទទួលបានការព្យាបាលត្រឹមត្រូវ ដែលអាចរក្សាបាននូវនិរន្តរភាព នៃប្រសិទ្ធភាពឱសថអង់ទីប៊ីយោទិក។"

**ចំណុចគួរស្វែងយល់**

**ហេតុអ្វីបានជាយើងប្រើប្រាស់ឱសថដែលមិនសមស្រប?**

យោងតាមអង្គការសុខភាពពិភពលោក ឱសថប្រមាណជា៥០ភាគរយ បានផ្តល់ឱ្យតាមវេជ្ជបញ្ជា ចែកចាយ និងលក់មិនត្រឹមត្រូវដោយរួមបញ្ចូលទាំងអ្នកជំងឺដែលលេបឱសថមិនត្រឹមត្រូវផងដែរ។[១] លើសពីនេះទៅទៀត មួយភាគបីនៃប្រជាជនសរុប មិនទទួលបាននូវឱសថជាមូលដ្ឋាន។ យោងទៅតាមគោលការណ៍ណែនាំរបស់អង្គការសុខភាពពិភពលោក ការប្រើប្រាស់ឱសថមិនសមស្របដែលកើតមានញឹកញាប់មានដូចខាងក្រោម៖

- អ្នកជំងឺប្រើឱសថច្រើនមុខ
- ការប្រើឱសថប្រឆាំងមេរោគមិនបានត្រឹមត្រូវ ដែលមិនមែនបង្ករោគដោយបាក់តេរី និងកម្រិតប្រើមិនត្រឹមត្រូវ
- ការប្រើលើសកម្រិតនៃឱសថចាក់ នៅពេលដែលឱសថលេបសមស្របជាង
- ការប្រើឱសថដោយខ្លួនឯងមិនសមស្រប
- វេជ្ជបណ្ឌិតមិនបានចេញវេជ្ជបញ្ជាសមស្របទៅតាមតាមគោលការណ៍ណែនាំក្នុងការព្យាបាល

ការប្រើប្រាស់ឱសថមិនសមស្របអាចនាំឱ្យជួបបញ្ហាធ្ងន់ធ្ងររហូតដល់ស្លាប់ ជាពិសេសចំពោះការបង្ករោគលើកូនក្មេង និងអ្នកជំងឺរ៉ាំរ៉ៃ។ ជំងឺរ៉ាំរ៉ៃមួយចំនួនទៀតដែលប៉ះពាល់ដោយសារការប្រើប្រាស់ឱសថមិនបានត្រឹមត្រូវមានដូចជា ជំងឺលើសសំពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺឆ្កួតជ្រូក និងជំងឺផ្លូវចិត្តជាដើម។ ការប្រើប្រាស់ឱសថមិនបានសមស្រប និងប្រើលើសកម្រិត គឺជាការខ្ជះខ្ជាយធនធាន ជាញឹកញាប់ធ្វើឱ្យអ្នកជំងឺចំណាយច្រើន ហើយបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់អ្នកជំងឺ ក្នុងលក្ខខណ្ឌដែលលទ្ធផលអ្នកជំងឺមិនសូវល្អ និងផលអាក្រក់នៃប្រតិកម្មឱសថ។

ការប្រើប្រាស់ឱសថមិនសមស្រប ឬការប្រើឱសថប្រឆាំងមេរោគលើសកម្រិត កំពុងតែបណ្ដាលឱ្យមានការកើនឡើងនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគ។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនបានត្រឹមត្រូវ អាចជំរុញដល់តម្រូវការដែលមិនត្រឹមត្រូវ ហើយនាំឱ្យមានការកាត់បន្ថយការទៅរកកន្លែងថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណ និងបាត់បង់ទំនុកចិត្តពីអ្នកជំងឺនៅក្នុងប្រព័ន្ធសុខាភិបាល។ បន្ទាប់មក នេះអាចនាំឱ្យមានវដ្តនៃការទិញឱសថអង់ទីប៊ីយោទិកដោយគ្មានវេជ្ជបញ្ជា និងទាមទារឱ្យមានឱសថអង់ទីប៊ីយោទិក ដែល "ខ្លាំង" "ខ្លាំងជាង" ឬ "ខ្លាំងបំផុត" ពីឱសថស្ថាន ឬកន្លែងថែទាំសុខភាព។

ដើម្បីបញ្ឈប់ការប្រើឱសថមិនបានសមស្រប គោលនយោបាយស្នូលទាំងអស់ត្រូវតែអនុវត្ត ដើម្បីលើកកម្ពស់ការប្រើឱសថឱ្យបានសមស្រប។ នេះរួមបញ្ចូលទាំងអស់ តែមិនកំណត់ចំពោះស្ថាប័នជាតិដែលសម្របសម្រួលគោលការណ៍នៃការប្រើប្រាស់ឱសថ គោលការណ៍វេជ្ជសាស្ត្រ ព័ត៌មានឯករាជ្យអំពីឱសថ និងការអប់រំសាធារណជនអំពីឱសថ។

**ពាក្យទាក់ទង៖** ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក ការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ

## សេចក្ដីយោង

[1] WHO (2002). “Promoting Rational Use of Medicines: Core Components”. *WHO*

## ជំពូក៤៖ ឱសថអង់ទីប៊ីយោទិកប្រើក្នុងផ្ទៃកបសុសត្វ

**ដែលផ្ដល់ចំណីសត្វមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក** *(គុណនាម)* ដែលពណ៌នាអំពីសត្វ ឬសាច់សត្វ រាល់ពេលដែលត្រូវបានគេផ្ដល់ឱសថអង់ទីប៊ីយោទិក តាមរយៈ អាហារ ឬទឹក ក្នុងដំណាក់កាលជីវិតរបស់វា។ ពាក្យនេះត្រូវបានប្រើញឹកញាប់បំផុតដើម្បីពណ៌នាអំពីការប្រើទៀងទាត់នៃឱសថអង់ទីប៊ីយោទិក ចំពោះសត្វដែលមានសុខភាពល្អ ក្នុងគោលបំណងណាមួយ។

> “លាមកដែលចេញពីសត្វស៊ីចំណីមានផ្ទុកឱសថអង់ទីប៊ីយោទិក អាចនឹងមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក និងបាក់តេរីដែលស៊ាំនឹងឱសថអង់ទីប៊ីយោទិក។”

> “ធម្មតាសាច់វេចខ្ចប់ជាច្រើនដែលយើងបរិភោគជាសត្វដែលស៊ីចំណីមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក។ ឱសថអង់ទីប៊ីយោទិក ត្រូវបានលាយក្នុងការផលិតចំណី ដើម្បីឱ្យសត្វលូតលាស់លឿនឆាប់ធំ និងការពារការបង្ករោគផ្សេងៗ។” [១]

## ចំណុចគួរស្វែងយល់

### តើយើងគួរតែព្រួយបារម្ភចំពោះការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ក្នុងការចិញ្ចឹមសត្វដែរឬទេ?

ជារៀងរាល់ថ្ងៃ នៅទូទាំងពិភពលោក ឱសថអង់ទីប៊ីយោទិកផ្ដល់ឱ្យសត្វជាច្រើនដូចជា គោ ក្របី មាន់ ជ្រូក ត្រី និងបង្គា។ [២] កសិករប្រើឱសថអង់ទីប៊ីយោទិកសម្រាប់ពន្លឿនការលូតលាស់ ការបង្ការការបង្ករោគ ឬការព្យាបាល។ ការប្រើឱសថអង់ទីប៊ីយោទិក ដើម្បីពន្លឿនការលូតលាស់ ត្រូវបានហាមឃាត់នៅទូទាំងពិភពលោក។ ទោះបីជាយ៉ាងណាក៏ដោយ បរិមាណឱសថអង់ទីប៊ីយោទិក ដែលត្រូវបានប្រើលើសត្វសរុប មិនត្រូវបានគេដឹងឡើយ ហើយប្រហែលជាមានការកើនឡើង ដោយសារតម្រូវការអាហារមានប្រភពពីសត្វក៏កើនឡើងផងដែរ។

គេបានប៉ាន់ប្រមាណថា ឱសថប្រឆាំងមេរោគប្រហែល ២០០ ០០០ ទៅ ២៥០ ០០០តោន កំពុងត្រូវបានផលិត និងប្រើប្រាស់ជារៀងរាល់ឆ្នាំនៅទូទាំងពិភពលោក។[២] ប្រមាណជា៧០%នៃឱសថប្រឆាំងមេរោគត្រូវបានប្រើប្រាស់លើសត្វ និង៣០%ទៀតលើមនុស្ស។ ឱសថអង់ទីប៊ីយោទិកដែលបានប្រើប្រាស់ដោយមនុស្ស និងសត្វភាគច្រើនត្រូវបានបញ្ចេញចោលតាមរយៈ ទឹកនោម និងលាមក ហើយហូរចូលទៅក្នុងប្រព័ន្ធលូទឹកស្អុយ និងបំពុល

ដល់បរិស្ថាន។ ក្រោយការប៉ះពាល់នឹងសារធាតុឱសថអង់ទីប៊ីយោទិក បាក់តេរីដែលរស់នៅក្នុងខ្លួនមនុស្ស និងសត្វអាចវិវត្តទៅជាស៊ាំនឹងឱសថអង់ទីប៊ីយោទិកផងដែរ ហើយបាក់តេរីទាំងនោះអាចចម្លងទៅដល់មនុស្សដទៃទៀត បរិស្ថាន និងបង្ក ឱ្យមានការឆ្លងរោគ និងស្លាប់ (រូបភាពទី១)។




រូបភាពទី១៖ ការស៊ាំនឹងឱសថអង់ទីប៊ីយោទិក៖ ពីកសិដ្ឋានទៅកាន់តុអាហារ។ [៤]

វាត្រឹមត្រូវណាស់ក្នុងការកត់សំគាល់ថា មានសុវត្ថិភាព ក្នុងការបរិភោគសាច់សត្វដែលស៊ីចំណីមានផ្ទុកសារធាតុ ឱសថអង់ទីប៊ីយោទិក ដែលត្រូវបានចិញ្ចឹមក្នុងកសិដ្ឋានដែលមានស្តង់ដាល្អត្រឹមត្រូវ។ នេះដោយសារតែសត្វដែលមកពីកសិដ្ឋានទាំងអស់នោះមិនត្រូវបានផ្តល់ចំណីមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក ក្នុងអំឡុងពេល១០ទៅ២០ថ្ងៃចុះក្រោយនៃជិវិត ដើម្បីឱ្យប្រាកដថាគ្មានសារធាតុឱសថអង់ទីប៊ីយោទិកនៅសេសសល់ក្នុងសាច់ទៀតទេ។ គួរបញ្ជាក់ផងដែរថា ការកែច្នៃសាច់ត្រូវតែស្អាត ដូច្នេះមិនមានបាក់តេរីនៅសល់លើសាច់នោះទេ។

លើសពីនេះទៀត ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក កាត់បន្ថយអត្រាការស្លាប់របស់សត្វពីជំងឺឆ្លង ក៏ដូចជាកាត់បន្ថយការរីករាលដាលនៃជំងឺទៅមនុស្ស និងសត្វដទៃទៀត។ សត្វដែលឆ្លងរោគដែលគ្មានចេញរោគសញ្ញាអាចបណ្តាលឱ្យឆ្លងជំងឺដល់មនុស្សតាមរយៈអាហារ។ អង្គការសុខភាពពិភពលោកកំពុងតែណែនាំឱ្យកសិករ និងឧស្សាហកម្មចំណីអាហារឱ្យឈប់ប្រើឱសថអង់ទីប៊ីយោទិកជាប្រចាំ ដើម្បីពន្លឿនការលូតលាស់ និងបង្ការជំងឺលើសត្វដែលមានសុខភាពល្អ។ [៥] សត្វដែលមានសុខភាពល្អគួរ

តែទទួលបានឱសថអង់ទីប៊ីយោទិក ដើម្បីការពារការបង្ករោគ ប្រសិនបើសត្វណាមួយនៅក្នុងចំណោមសត្វដទៃទៀតនៅក្នុងក្រោល ហ្វូង ឬក្រុមសត្វដូចគ្នា ត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថាមានការបង្ករោគដោយបាក់តេរី។ ដូច្នេះការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ចំពោះការកែច្នៃអាហារពីសត្វនៅតែមានសារៈសំខាន់ក្នុងឧស្សាហកម្មចិញ្ចឹមសត្វ  និងការលុបបំបាត់ទាំងស្រុងអាចនឹងបណ្តាលឱ្យមានបញ្ហាជាច្រើន។

សរុបមក យើងគួរតែយកចិត្តទុកដាក់អំពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសត្វ ហើយយ៉ាងហោចណាស់យើងគួរតែកាត់បន្ថយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើមនុស្ស និងសត្វឱ្យនៅសល់កម្រិតទាបបំផុត។

## សេចក្តីយោង


[1] Arsenault C. (2015). "A huge spike in antibiotics-fed livestock is bringing the superbug epidemic even faster than feared". *Businessinsider.com*

[2] Grace Communication Foundation (2018). "Antibiotics". *Sustainabletable.org*

[3] O'Neill J. (2015). "Antimicrobials in agriculture and the environment: reducing unnecessary use and waste." *Amr-review.org.*

[4] CDC (2013).  "From farm to table". *Cdc.gov*

[5] WHO (2017). "Stop using antibiotics in healthy animals to prevent the spread of antibiotic resistance". *Who.int*


## សារធាតុដែលគ្មានផ្ទុកឱសថអង់ទីប៊ីយោទិក

*(គុណនាម)* ដែលគ្មានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិកជាពិសេសសម្រាប់ផលិតផលសាច់សត្វ។

"ពាក្យ 'សរីរាង្គ' 'គ្មានផ្ទុកធាតុឱសថអង់ទីប៊ីយោទិក'  'គ្មានការកែប្រែហ្សែន' ត្រូវការបញ្ជាក់ឱ្យច្បាស់លាស់។"

"សាច់វេចខ្ចប់ជាច្រើនដែលយើងបរិភោគធម្មតាបានមកពីសត្វដែលផ្តល់ចំណីដែលមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក។  ទោះបីជាយ៉ាងណាក៏ដោយ  សត្វទាំងអស់នោះមិនត្រូវបានផ្តល់ចំណីដែលមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក  ក្នុងអំឡុងពេលពីរសប្តាហ៍ចុងក្រោយឡើយ។ ដូច្នេះសាច់សត្វគឺគ្មានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិកទេ។"

"មិនមានស្តង់ដាពិភពលោក ឬវិញ្ញាបនបត្រសម្រាប់ពាក្យ ឬស្លាកសញ្ញា 'គ្មានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក' នោះទេ។"

## ចំណុចគួរស្វែងយល់

### សាច់ដែលមានស្លាកថា “គ្មានសារធាតុឱសថអង់ទីប៊ីយោទិក” គឺកំពុងធ្វើអោយការយល់ច្រឡំ

សាច់សត្វ ឬផលិតផលសាច់សត្វដែលបានដាក់ស្លាក ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’ គឺជម្មតាមិនមានផ្ទុក ឬយ៉ាងហោចណាស់រកមិនឃើញនូវសារធាតុឱសថអង់ទីប៊ីយោទិក ។ អតិថិជនអាចនឹងជឿខុសថា សាច់សត្វដែលបានបិទស្លាកគ្មានសារធាតុឱសថអង់ទីប៊ីយោទិក ត្រូវបានយកមកពីសត្វដែលចិញ្ចឹមដោយគ្មានផ្តល់ឱសថអង់ទីប៊ីយោទិក។

នៅប្រទេសអភិវឌ្ឍន៍ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកទាំងអស់ក្នុងកសិដ្ឋានបានកំណត់យ៉ាងតឹងរឹង និងមានរយៈពេលកំណត់មិនឱ្យឱសថអង់ទីប៊ីយោទិក គឺត្រូវបានបង្កើតឡើងដើម្បីជៀសវាងពីការសេសសល់នៃសារធាតុឱសថអង់ទីប៊ីយោទិកនៅក្នុងផលិតផលសាច់ និងទឹកដោះ។ នៅសហរដ្ឋអាមេរិក ពាក្យ ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’ មិនត្រូវបានអនុញ្ញាតឱ្យដាក់ស្លាកលើផលិតផលសាច់ ឬបសុបក្សីទេ។[១] ទោះបីជាយ៉ាងណាក៏ដោយ ពាក្យ ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’ ត្រូវបានអនុញ្ញាតឱ្យដាក់ស្លាកលើផលិតផលដែលធ្វើពីទឹកដោះគោដូចជា លើប្រអប់ទឹកដោះគោ ដែលត្រូវបានកំណត់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA)។ រដ្ឋបាលចំណីអាហារ និងឱសថមិនបានការកំណត់ទាក់ទងនឹងនិយមន័យនៃពាក្យ ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’ ទេ ប៉ុន្តែគេរំពឹងថា វាមានន័យថាគ្មានសំណល់ឱសថអង់ទីប៊ីយោទិកនៅក្នុងផលិតផលនោះទេ។ នេះមានន័យថា រដ្ឋបាលចំណីអាហារ និងឱសថ (FDA) មិនបានបញ្ជាក់ពាក្យ ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’ ឬក៏គ្មានការបញ្ជាក់ពីភ្នាក់ងារដែរ។ លើសពីនេះទៅទៀត ពាក្យ ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’ មិនមានការធានាថា សត្វគោទាំងអស់នោះមិនត្រូវបានគេព្យាបាលដោយឱសថអង់ទីប៊ីយោទិក  ឬឱសថផ្សេងទៀតនោះទេ។ សូមកត់សំគាល់ថា មិនមានស្តង់ដាជាសកល ឬការកំណត់និយមន័យនៃពាក្យ ‘គ្មានសារធាតុឱសថអង់ទីប៊ីយោទិក’នោះទេ។

ការជ្រើសរើសផលិតផលសត្វដែលបានមកពីការចិញ្ចឹមដោយគ្មានផ្តល់ឱសថអង់ទីប៊ីយោទិកត្រូវបានគេលើកឡើង ជាជំហានដ៏សំខាន់មួយដែលអ្នកប្រើប្រាស់ អាចយកទៅជួយដោះស្រាយវិបត្តិសុខភាពសាធារណៈនៃភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ។ ការចិញ្ចឹមសត្វដោយមិនប្រើឱសថអង់ទីប៊ីយោទិក អាចធ្វើទៅបាន ប្រសិនបើការរក្សាអនាម័យធ្វើឱ្យប្រសើរឡើងហើយការអនុវត្តការគ្រប់គ្រងដើម្បីទប់ស្កាត់ជំងឺត្រូវបានអនុវត្ត។

**ពាក្យទាក់ទង៖** ការចិញ្ចឹមសត្វដោយគ្មានឱសថអង់ទីប៊ីយោទិក ដែលផ្តល់ចំណីមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក

## សេចក្តីយោង

[1] Greener Choices (2017). “Antibiotic Free- What this claim means”. *Greenerchoice.org*

## ឱសថអង់ទីប៊ីយោទិកដែលសំខាន់ចាំបាច់ (CIA)

*(នាម)* ឱសថអង់ទីប៊ីយោទិកត្រូវបានគេចាត់ទុកថាជាឱសថដ៏សំខាន់ សម្រាប់សុខភាពមនុស្ស ដើម្បីដោះស្រាយផលវិបាកនៃសុខភាពសាធារណៈដែលត្រូវបានផ្សាភ្ជាប់ជាមួយនឹងការប្រើប្រាស់ក្រុមឱសថប្រឆាំងមេរោគ នៅក្នុងផលិតផលអាហារដែលផលិតពីសត្វ។ បញ្ជីឱសថអង់ទីប៊ីយោទិកទាំងនេះត្រូវបានបង្កើតឡើងដោយអង្គការសុខភាពពិភពលោក។

“នៅប្រទេសអភិវឌ្ឍន៍ កសិដ្ឋានជាច្រើនបានបញ្ឈប់ទាំងស្រុងនូវការប្រើប្រាស់នូវឱសថអង់ទីប៊ីយោទិកសំខាន់ចាំបាច់ដែលជាអតិភាពបំផុត។”

“ក្រុមហ៊ុនផ្គត់ផ្គង់សាច់សត្វត្រូវបានស្នើឱ្យចាប់ផ្តើមកាត់បន្ថយការប្រើឱសថអង់ទីប៊ីយោទិក ដែលកំណត់ដោយអង្គការសុខភាពពិភពលោកថា ជាឱសថអង់ទីប៊ីយោទិកសំខាន់ចាំបាច់ជាអតិភាព

## ពាក្យស្រដៀង

**ឱសថអង់ទីប៊ីយោទិកដែលសំខាន់ក្នុងវេជ្ជសាស្ត្រ**

*(នាម)* ឱសថអង់ទីប៊ីយោទិកប្រើសម្រាប់ព្យាបាលមនុស្ស ដែលបានចុះបញ្ជីដោយអង្គការសុខភាពពិភពលោក។

### ចំណុចគួរស្វែងយល់

### ឱសថអង់ទីប៊ីយោទិកសំខាន់ចាំបាច់សម្រាប់សុខភាពមនុស្សត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ

ចាប់តាំងពីឆ្នាំ២០០៥ អង្គការសុខភាពពិភពលោកតែងតែធ្វើបច្ចុប្បន្នភាពលើបញ្ជីកំណត់ត្រានៃឱសថប្រឆាំងមេរោគទាំងអស់ ដែលសព្វថ្ងៃនេះប្រើសម្រាប់មនុស្ស (ដែលភាគច្រើនប្រើលើផ្នែកបសុពេទ្យផងដែរ) បានចែកជា៣ក្រុម ដោយផ្អែកលើសារៈសំខាន់របស់វាលើមនុស្ស។ បញ្ជីនេះមានគោលបំណង ដើម្បីជួយក្នុងការគ្រប់គ្រងភាពស៊ាំនឹង ឱសថប្រឆាំងមេរោគដែលធានាថា ឱសថប្រឆាំងមេរោគទាំងអស់នោះ ជាពិសេសឱសថប្រឆាំងមេរោគសំខាន់ចាំបាច់ ត្រូវបានប្រើដោយប្រុងប្រយ័ត្នចំពោះមនុស្សនិងសត្វ។

ក្នុងឆ្នាំ២០១៦ ការពិនិត្យឡើងវិញលើកទី៥នៃ *ឱសថប្រឆាំងមេរោគសំខាន់ចាំបាច់* សម្រាប់មនុស្សត្រូវបានចេញផ្សាយដោយអង្គការសុខភាពពិភពលោក។[១] ការសន្និដ្ឋានពីសិក្ខាសាលាដោយអ្នកជំនាញដែលរៀបចំឡើងដោយអង្គការសុខភាពពិភពលោកមានដូចខាងក្រោម:

១. មានភស្តុតាងច្បាស់លាស់ពីផលប៉ះពាល់ដល់សុខភាពមនុស្ស ដោយសារមេរោគដែលមានភាពស៊ាំនឹងឱសថដែលបណ្តាលមកពីការប្រើឱសថប្រឆាំងមេរោគដែលមិនត្រូវប្រើលើមនុស្ស។

២. បរិមាណ និងគំរូនៃការប្រើឱសថប្រឆាំងនឹងមេរោគដែលមិនត្រូវដាក់អោយប្រើលើមនុស្ស បានប៉ះពាល់ដល់ការកើតឡើងនៃភាពស៊ាំរបស់បាក់តេរីនៅលើសត្វ និងលើម្ហូបអាហារ ដែលជាហេតុធ្វើឱ្យមនុស្សមានការប៉ះពាល់ទៅនឹងបាក់តេរីដែលមានភាពស៊ាំនឹងឱសថទាំងអស់នោះ។

៣.ផលវិបាកនៃភាពស៊ាំនឹងឱសថប្រឆាំងមេរោគគឺធ្ងន់ធ្ងរ ជាពិសេសនៅពេលដែលមេរោគស៊ាំនឹងឱសថប្រឆាំងមេរោគដែលមានសារៈសំខាន់ចាំបាច់សម្រាប់មនុស្ស។

វាគួរឱ្យកត់សំគាល់ដែរថា ឱសថខ្លះប្រើលើសត្វ ដូចជាឱសថ Tilmicosin មិនត្រូវបានប្រើលើមនុស្សទេ ប៉ុន្តែវាត្រូវបានគេចាត់ទុកថាជាឱសថអង់ទីប៊ីយោទិកដែលមានសារៈសំខាន់ចាំបាច់ ពីព្រោះវាស្ថិតក្នុងក្រុមដូចគ្នា(macrolides) និងឱសថអង់ទីប៊ីយោទិកប្រើសម្រាប់មនុស្សដែរ។ ការប្រើលើសកម្រិត និងមិនត្រឹមត្រូវនៃឱសថ Tilmicosin ក្នុងការ

ចិញ្ចឹមសត្វអាចធ្វើឱ្យមានការកើនឡើង និងរីករាលដាលនៃបាក់តេរីដែលស៊ាំនឹងឱសថក្រុម Macrolides។

ជាឧទាហរណ៍នៅសហរដ្ឋអាមេរិកបានបង្ហាញថាហ្សែន mcr-1 ត្រូវបានគេរកឃើញក្នុងបាក់តេរីឈ្មោះ *Escherichia coli* នៅក្នុងខ្លួនស្ត្រីម្នាក់មកពីរដ្ឋ Pennsylvania ដែលមានការបង្ករោគក្នុងប្រព័ន្ធទឹកម្ូត្រ។ បាក់តេរីដែលមានផ្ទុកហ្សែន mcr-1 មានភាពស៊ាំទៅនឹងឱសថអង់ទីប៊ីយោទិកឈ្មោះ Colistin។ នាយកដ្ឋានកសិកម្មនៃសហរដ្ឋអាមេរិកបានរាយការណ៍ឱ្យដឹងថា ហ្សែននេះត្រូវបានរកឃើញនៅក្នុងវត្ថុវិភាគ នៃពោះវៀនតូចរបស់សត្វជ្រូក។ ឱសថនេះត្រូវបានគេចាត់ទុកថាជាឱសថអង់ទីប៊ីយោទិកប្រើចុងក្រោយគេដែលអាចព្យាបាលការបង្ករោគដែលបង្កដោយបាក់តេរីដែលបានអភិវឌ្ឍភាពស៊ាំរបស់ខ្លួនទៅនឹងឱសថអង់ទីប៊ីយោទិកជាច្រើនប្រភេទ។ [២] Colistin ត្រូវបានចាត់ទុកជាឱសថប្រឆាំងមេរោគដែលមានសារៈសំខាន់ចាំបាច់ និងមិនគួរប្រើយ៉ាងទូលំទូលាយក្នុងកសិកម្មចិញ្ចឹមសត្វទេ។ ប្រទេសចិនថ្មីៗនេះ បានហាមឃាត់ការប្រើឱសថ Colistin សម្រាប់ពន្លឿនការលូតលាស់ និងបានចេញអាណត្តិគ្រប់គ្រងការប្រើ Colistin ក្នុងការព្យាបាលជំងឺសត្វ។

**ពាក្យទាក់ទង៖** ដែលផ្តល់ចំណីមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក Antibiotic footprints

## សេចក្តីយោង

[1] WHO (2017). "WHO guidelines on use of medically important antimicrobials in food-producing animals." (Online ed.). *WHO*. ISBN: 978 92 4 155013 0

[2] Branswell H. (2016). "The world's worst superbug has made its way to the US." *Businessinsider.com*

## ការចិញ្ចឹមសត្វដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិក (RWA)

*(នាម)* ការពណ៌នាអំពីសត្វពាហនៈ ឬសាច់សត្វដែលមិនត្រូវបានផ្តល់ឱសថអង់ទីប៊ីយោទិកណាមួយក្នុងជីវិតរបស់វា ជាពិសេសក្នុងចំណីអាហារ។

> “ភោជនីយដ្ឋានអាហាររហ័សមួយចំនួននៅប្រទេសអភិវឌ្ឍបម្រើម្ហូបដែលបានមកពីសាច់សត្វដែលចិញ្ចឹមដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិកតែប៉ុណ្ណោះ។”

> “តម្លៃនៃសាច់បានមកពីសត្វដែលចិញ្ចឹមដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិក មានតម្លៃថ្លៃនៅក្នុងប្រទេសកំពុងអភិវឌ្ឍ។ វាមិនទាន់ច្បាស់ទេថាតើមនុស្សជាច្រើននឹងស្ម័គ្រចិត្តចំណាយ២០% បន្ថែមសំរាប់សាច់សត្វដែលចិញ្ចឹមដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិកនោះទេ។”

### ពាក្យស្រដៀង

**ដែលគ្មានឱសថអង់ទីប៊ីយោទិករហូត**(NAE)

*(គុណនាម)* ពាក្យដូចគ្នាទៅនឹង ‘ការចិញ្ចឹមដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិក’។

> “សត្វដែលត្រូវការឱសថអង់ទីប៊ីយោទិក ត្រូវបានដកចេញពីក្រុម ‘ដែលគ្មានសារធាតុឱសថអង់ទីប៊ីយោទិក រហូត’ និងត្រូវបានបញ្ជូនឱ្យនៅជាមួយក្រុមសត្វដែលចិញ្ចឹមធម្មតា។”

### ចំណុចគួរស្វែងយល់

## ការចិញ្ចឹមដោយមិនផ្តល់ឱសថអង់ទីប៊ីយោទិក៖ អតីតកាល បច្ចុប្បន្នកាល និងអនាគតកាល

ក្នុងឆ្នាំ២០០៧ ក្រុមហ៊ុនបសុបក្សីជាច្រើននៅសហរដ្ឋអាមេរិកបានចាប់ផ្តើមផ្សព្វផ្សាយផលិតផលរបស់ពួកគេដោយការចិញ្ចឹមមិនផ្តល់ឱសថអង់ទីប៊ីយោទិក ។ [១] ទោះបីជាវាចំណាយប្រាក់ច្រើន ដើម្បីចិញ្ចឹមសត្វដោយមិនប្រើឱសថអង់ទីប៊ីយោទិកក្តី ក៏ក្រុមហ៊ុននៅតែបន្ត ដោយសារតែអតិថិជននៅអាមេរិកនៅតែហ៊ានចំណាយប្រាក់ទិញក្នុងតម្លៃខ្ពស់ ក្នុងដំណើរការមួយនេះ។ នៅឆ្នាំ២០១៥ សង្វាក់ផលិតចំណីអាហាររហ័សជាច្រើននៅសហរដ្ឋអាមេរិកបានប្រកាសថាភោជនីយដ្ឋានរបស់ពួកគេនឹងបម្រើតែប្រូតេអ៊ីនចេញពីសត្វដែលមិនធ្លាប់ប្រើឱសថអង់ទីប៊ីយោទិកប៉ុណ្ណោះ។ នេះជាសេចក្តីថ្លែងការមួយដោយអតិថិជន និងសុខភាពសាធារណៈបានដាក់សម្ពាធលើហាងអាហាររហ័ស

ដើម្បីកាត់បន្ថយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកនៅក្នុងប្រភពសាច់សត្វ។[២]

យ៉ាងណាក៏ដោយ ការចិញ្ចឹមសត្វដោយមិនផ្ដល់ឱសថអង់ទីប៊ីយោទិក តម្រូវឱ្យមានប្រព័ន្ធគ្រប់គ្រងល្អ។ កសិករចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងនូវអនាម័យ និងការអនុវត្តការគ្រប់គ្រងដែលអាចទប់ស្កាត់ជំងឺ និងស្លាប់។ ទាំងនេះរួមបញ្ចូលទាំងការកែលម្អការរៀបចំក្រោលសត្វ ការកាត់បន្ថយដង់ស៊ីតេសត្វ ការផ្ដល់ Probiotics និងឱសថរុក្ខជាតិ។ ប្រសិនបើសត្វមានការបង្ករោគដោយបាក់តេរី ឱសថអង់ទីប៊ីយោទិកគួរតែត្រូវបានផ្ដល់ ហើយសត្វត្រូវបានលក់ក្នុងប្រភេទផ្សេង។

បច្ចុប្បន្នផលិតផលដែលបានមកពី ‘ការចិញ្ចឹមសត្វដោយមិនផ្ដល់ឱសថអង់ទីប៊ីយោទិក’ មានតម្លៃថ្លៃខ្លាំង ឬមិនមានលក់នៅក្នុងបណ្ដាប្រទេសមានប្រាក់ចំណូលទាប និងមធ្យម។ ការផ្លាស់ប្ដូរទៅ ‘ចិញ្ចឹមសត្វដោយមិនផ្ដល់ឱសថអង់ទីប៊ីយោទិក’ ដោយគ្មានការគ្រប់គ្រងត្រឹមត្រូវ អាចបណ្ដាលឱ្យមានសត្វស្លាប់។ ដូចគ្នានេះដែរ ការយល់ដឹងរបស់អតិថិជន ឬការទិញ នៅក្នុងបណ្ដាប្រទេសមានប្រាក់ចំណូលទាបនិងមធ្យម នៅមានកំរិតដែលអាចជាមូលហេតុមិនអាចទ្រទ្រង់ការវិនិយោគក្នុងការកែលម្អការគ្រប់គ្រង និងអនុវត្តអនាម័យ។ ចំពោះបណ្ដាប្រទេសមានប្រាក់ចំណូលទាប និងមធ្យមត្រូវការ ការគាំទ្រពីរដ្ឋាភិបាលអង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋខ្លួនពិតជាមានសារៈសំខាន់ក្នុងការការផ្លាស់ប្ដូរកែរសម្រួលនូវចំនុងដ៏សំខាន់មួយនេះ។

**ពាក្យទាក់ទង៖** គ្មានសារធាតុឱសថអង់ទីប៊ីយោទិក ដែលផ្ដល់ចំណីមានផ្ទុកសារធាតុឱសថអង់ទីប៊ីយោទិក

## សេចក្ដីយោង

[១] Ritchie H (2014). “Perdue Foods sets new standard for antibiotic-free chicken”. *Sustainablebrands.com*

[២] Smith T.C. (2015). “What does ‘meat raised without antibiotics’ mean- and why is it important?” (Online ed.). *Washingtonpost.com*

# ជំពូក៥៖ យុទ្ធនាការប្រយុទ្ធប្រឆាំងភាពស៊ាំនឹងឱសថប្រឆាំងមេរោគ

## សប្តាហ៍យល់ដឹងអំពីឱសថអង់ទីប៊ីយោទិកសកល

*(នាម)* ជាយុទ្ធនាការដែលមានគោលបំណងផ្សព្វផ្សាយទៅដល់សាធារណជនទូទៅ បុគ្គលិកសុខាភិបាល និងអ្នកបង្កើតច្បាប់ឱ្យបានយល់ដឹងច្បាស់អំពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ក៏ដូចជាការឆ្លើយតបទៅនឹងការកើនឡើងនៃភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកជាសកល។ យុទ្ធនាការនេះបានរៀបចំឡើងដោយអង្គការសុខភាពពិភពលោក (WHO) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) និងអង្គការសុខភាពសត្វពិភពលោក (OIE)។

> “សប្តាហ៍យល់ដឹងអំពីឱសថអង់ទីប៊ីយោទិកសកល រៀបចំចាប់ពីថ្ងៃទី១២-១៨ ខែវិច្ឆិកា ឆ្នាំ២០១៨។”

## ចំណុចគួរស្វែងយល់

### ការគ្រប់គ្រងឱសថអង់ទីប៊ីយោទិកដោយប្រុងប្រយ័ត្ន

ក្នុងអំឡុងពេលសប្តាហ៍យល់ដឹងអំពីឱសថអង់ទីប៊ីយោទិកសកល អង្គការសុខភាពពិភពលោក និងអង្គការដៃគូសហការនឹងផ្សព្វផ្សាយទៅដល់សាធារណជនទូទៅឱ្យយល់ដឹងពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក តាមរយៈ បណ្តាញសង្គម សិក្ខាសាលា សំណួរ/ចម្លើយ និងសកម្មភាពការងារជោគជ័យនានា។ អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិ (FAO) អង្គការសុខភាពពិភពលោក (WHO) និងអង្គការសុខភាពសត្វពិភពលោក (OIE) រួមគ្នាអំពាវនាវឱ្យមានការចូលរួមកាត់បន្ថយការកើនឡើងនៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើមនុស្ស និងសត្វ។ នៅឆ្នាំ២០១៧ មានប្រធានបទមួយចំណងជើងថា៖ “ចូរស្វែងរកការណែនាំពីបុគ្គលិកសុខាភិបាលដែលប្រកបដោយវិជ្ជាជីវៈ មុននឹងប្រើប្រាស់ឱសថអង់ទីប៊ីយោទិក។” [១]

ដោយឱសថអង់ទីប៊ីយោទិកគឺជាធនធានដ៏មានតម្លៃ វាពិតជាសំខាន់ណាស់ដែលអ្នកត្រូវសុំការណែនាំដែលត្រឹមត្រូវពីវេជ្ជបណ្ឌិត និងបុគ្គលិកសុខាភិបាល មុនប្រើប្រាស់។ ការស្វែងរកការណែនាំនេះ មិនមែនផ្តល់សារៈប្រយោជន៍តែលើរូបអ្នកប៉ុណ្ណោះទេ ប៉ុន្តែវាក៏ផ្តល់ដល់ក្រុមគ្រួសារ និងសហគមន៍របស់អ្នកផងដែរ ក្នុងការចូលរួមកាត់បន្ថយការរីករាលដាលនៃភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក។ “ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវអាចបង្កឱ្យពួកយើងជួបហានិភ័យ។” [២] ម្យ៉ាងទៀត ដោយយោងតាមអង្គការសុខភាពពិភពលោក យុទ្ធនាការនេះមានគោលបំណងដូចខាងក្រោម៖

- ឱ្យពិភពលោកស្គាល់ពីភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកដែលប៉ះពាល់ដល់សុខភាពធ្ងន់ធ្ងរ

- លើកកម្ពស់ការយល់ដឹងអំពីការរក្សាប្រសិទ្ធភាពនៃឱសថអង់ទីប៊ីយោទិក តាមរយៈការប្រើប្រាស់ឱ្យបានត្រឹមត្រូវ ។
- បង្កើនការទាក់ទាញចំណាប់អារម្មណ៍ពីបុគ្គលគ្រប់រូប បុគ្គលិកសុខាភិបាល និងអ្នកជំនាញខាងផ្នែកកសិកម្ម និងរាជរដ្ឋាភិបាលដែលគួរដើរតួនាទីយ៉ាងសំខាន់ក្នុងការដោះស្រាយបញ្ហាភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិកនេះ។
- លើកទឹកចិត្តដល់ការផ្លាស់ប្ដូរឥរិយាបថ និងការបញ្ជូនសារ ដែលជាសកម្មភាពសាមញ្ញអាចធ្វើឱ្យមានផ្លាស់ប្ដូរដល់ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក។
-

លោកអ្នកអាចតាមដានព័ត៌មានថ្មីៗអំពីយុទ្ធនាការនេះ តាមរយៈ #AntibioticResistance និង #StopSuperbugs នៅលើទំព័រ twitter Facebook និង Instagram ។

## សេចក្ដីយោង

១ WHO (2017). "Use antibiotics wisely to combat rising drug resistance". *Who.int*

២ WHO (2017). "World Antibiotic Awareness Week 2017". *Who.int*

## ស្នាមជើង ឱសថអង់ទីប៊ីយោទិក (Antibiotic Footprint)

*(នាម)* គឺជារង្វាស់មួយប្រើប្រាស់ក្នុងការបរិយាយអំពីបរិមាណសរុប នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ដោយសកម្មភាពមនុស្សផ្ទាល់ និងប្រយោល នៅលើមនុស្ស និងសត្វក្នុងផលិតកម្មកសិកម្ម។

> "Antibiotic Footprint អាចជួយអ្នកឱ្យដឹងអំពីចំនួន នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសរុប នៅជុំវិញពិភពលោក។" [១]

> "តើយើងអាចជួយកាត់បន្ថយចំនួន Antibiotic Footprint តាមរបៀបណា?"

## ចំណុចគួរស្វែងយល់

### តើអ្វីទៅជា Antibiotic Footprint?

Antibiotic Footprint ត្រូវបានលើកឡើងថា ជារង្វាស់សកលមួយដែលបរិយាយអំពីបរិមាណសរុប នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកនៅលើមនុស្ស និងផ្នែកបសុសត្វ ដែលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី។ [១] 'Carbon footprint' និង 'Antibiotic footprint' ត្រូវបានគេសម្គាល់ឃើញមានលក្ខណៈស្រដៀងគ្នា (រូបភាពទី១) ។ ខណៈដែលយើងគ្រប់គ្នាប្រើប្រាស់កម្លាំងថាមពលដើម្បីរស់រានមាន

ជីវិត ការប្រើប្រាស់ផូស៊ីលឥន្ធនៈយ៉ាងច្រើនសន្ធឹកសន្ធាប់ បានជំរុញឱ្យមានការផ្លាស់ប្តូរអាកាសធាតុពិភពលោកផងដែរ។ ដូចគ្នានេះដែរ ខណៈពេលដែលយើងប្រើប្រាស់ឱសថអង់ទីប៊ីយោទិក ដើម្បីប្រឆាំងនឹងការបង្ករោគដោយបាក់តេរី ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងមិនត្រឹមត្រូវ បានជំរុញឱ្យបាក់តេរីទាំងនោះក្លាយជាមេរោគស៊ាំនឹងឱសថច្រើនមុខ (Superbugs) ដែលជាបាក់តេរីស៊ាំទៅនឹងឱសថអង់ទីប៊ីយោទិកច្រើនប្រភេទ។




**រូបភាពទី១**: Carbon Footprint (ខាងឆ្វេង) និង Antibiotic Footprint (ខាងស្តាំ)

ប្រសិនបើគ្មានសកម្មភាពជាសកល ដើម្បីកាត់បន្ថយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកនោះទេ មនុស្សជាច្រើននឹងត្រូវស្លាប់ដោយមេរោគស៊ាំនឹងឱសថច្រើនមុខដ៏សាហាវនេះ។ Antibiotic Footprint ក៏មានគោលបំណងវាស់វែងបរិមាណសរុប នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកនៅគ្រប់សកម្មភាពរបស់មនុស្សដោយផ្ទាល់នៅក្នុងសហគមន៍ មន្ទីរពេទ្យ និងដោយប្រយោលក្នុងផលិតផលកសិកម្មផងដែរ។

Antibiotic Footprint នៃប្រទេសមួយអាចប៉ាន់ប្រមាណពីចំនួនប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសរុបនៅលើមនុស្ស និងសត្វ (រូបភាពទី២)។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកនៅក្នុងវិស័យកសិកម្ម ជាផ្នែកមួយសំខាន់របស់ Antibiotic Footprint ពីព្រោះឱសថអង់ទីប៊ីយោទិកជាច្រើនត្រូវបានគេយកទៅផ្តល់ជាចំណីសត្វ ហើយហូរចូលក្នុងប្រព័ន្ធលូទឹកស្អុយ និងប្រភពទឹកផ្សេងទៀត ដោយមិនបានបន្សុទ្ធដែលធ្វើឱ្យមានការកើនឡើងបាក់តេរីស៊ាំនឹងឱសថអង់ទីប៊ីយោទិកនៅក្នុងបរិស្ថាន។




**រូបភាពទី២៖** Antibiotic Footprints សកល តាមប្រទេស នៅឆ្នាំ២០១៥

ចូរស្វែងរកបន្ថែមអំពី “Antibiotic Footprint” នៅលើគេហទំព័រ www.antibioticfootprint.net

**ពាក្យទាក់ទង៖** ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ

## សេចក្តីយោង


១ Antibioticfootprint.net
២ Keen PL, Patrick DM (2013). “Tracking change: a look at the ecological footprint of antibiotics and antimicrobial resistance.” *Antibiotics.* 2(2): 191-205. DOI: 10.3390/antibiotics2020191


## ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដ៏ឆ្លាតវៃ

*(នាម)* វាជាយុទ្ធនាការលើកកម្ពស់ចំណេះដឹងអំពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសមស្រម នៅប្រទេសថៃ ចាប់ផ្តើមតាំងពីឆ្នាំ២០០៧។

“គោលការណ៍ទីមួយ នៃកម្មវិធីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដ៏ឆ្លាតវៃ គឺ “គ្មានឱសថអង់ទីប៊ីយោទិកណាអាចព្យាបាលការបង្ករោគដែលមិនមែនបង្កដោយបាក់តេរីបានទេ” ។” [១]

## ចំណុចគួរស្វែងយល់

## ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដ៏ឆ្លាតវៃ” នៅប្រទេសថៃ

នៅឆ្នាំ២០១០ ភាពស៊ាំនឹងឱសថប្រឆាំងមេរោគបានធ្វើឱ្យប្រជាជនថៃស្លាប់ប្រមាណជា ១៩ ០០០នាក់បន្ថែម ។[១] នៅប្រទេសថៃ ឱសថអង់ទីប៊ីយោទិកអាចរកទិញបានដោយគ្មានវេជ្ជបញ្ជា ទើបឃើញមានការប្រើប្រាស់មិនត្រឹមត្រូវក្នុងចំណោមបុគ្គលិកសុខាភិបាល និងសាធារណជនទូទៅ។[២] គេបានប៉ាន់ប្រមាណថាតិចជាង ១០ភាគរយនៃជំងឺផ្តាសាយធម្មតាមានការភាន់ច្រឡំថា វាបង្ករោគដោយបាក់តេរី ប៉ុន្តែនៅប្រទេសថៃ ឱសថអង់ទីប៊ីយោទិកត្រូវបានចេញវេជ្ជបញ្ជាជាទូទៅសម្រាប់ព្យាបាលផ្តាសាយធម្មតានេះ ដោយបុគ្គលិកសុខាភិបាលនៅមន្ទីរពេទ្យ វេជ្ជបណ្ឌិតនៅ

តាមគ្លីនិក និងឱសថករនៅឱសថស្ថានជាដើម ហើយពេលខ្លះត្រូវបានស្នើសុំដោយផ្ទាល់ពីអ្នកជំងឺ។ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវអាចផ្តល់គ្រោះថ្នាក់ដល់សុខភាពអ្នកជំងឺ និងមនុស្សគ្រប់គ្នាក្នុងប្រទេស។

កម្មវិធី “ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដ៏ឆ្លាតវៃ” ត្រូវបានប្រទេសថៃលើកឡើងជាកម្មវិធីគំរូមួយក្នុងការលើកកម្ពស់ការប្រើប្រាស់ឱសថដែលសមស្រប ដោយចាប់ផ្តើមពីឱសថអង់ទីប៊ីយោទិក។ [២] គោលដៅ ៣សំខាន់ៗ ដែលបានកំណត់ក្នុងកម្មវិធីនេះ មានដូចជា៖ (១)ជំងឺផ្តាសាយធម្មតាជាមួយនឹងការឈឺបំពង់ក (២)ជំងឺរាកស្រួចស្រាវ (៣)របួសស្រាលដែលភាគច្រើនយើងមិនបាច់ត្រូវការឱសថអង់ទីប៊ីយោទិក។ កម្មវិធីនេះ មានចំនួន៣ដំណាក់កាល៖ ដំណាក់កាលទី១ គឺប៉ាន់ប្រមាណលើបទអន្តរាគមន៍ដែលមានគោលបំណងផ្លាស់ប្តូរឥរិយាបថ នៃការចេញវេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត ដំណាក់កាលទី២៖ ពិនិត្យមើលភាពងាយស្រួល ក្នុងការដំណើរការកម្មវិធី និងដំណាក់កាលទី៣៖ ផ្តោតលើការលើកកម្ពស់ប្រកបដោយនិរន្តរភាព។ [៣]

យើងឃើញមានយុទ្ធនាការជាច្រើននៅតាមបណ្តាប្រទេសនានាក្នុងពិភពលោក ដែលបានបង្ហាញពីការលើកកម្ពស់ចំណេះដឹង និងដោះស្រាយបញ្ហាភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ដូចជា Antibiotic Guardian និង សប្តាហ៍យល់ដឹងអំពីឱសថអង់ទីប៊ីយោទិកសកល ជាដើម។




**រូបភាពទី១៖** ស្លាកសញ្ញា នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដ៏ឆ្លាតវៃ

**ពាក្យទាក់ទង៖** ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក ការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ ការប្រើប្រាស់ឱសថដែលសមស្រប ជំងឺផ្តាសាយធម្មតា ជំងឺរាក

## សេចក្តីយោង

[១] Sumpradit N., Chongtrakul P., Anuwong K., et al (2012). “Antibiotic Smart Use: a workable model for promoting the rational use of medicine in Thailand”. *Bulletin of the World Health Organization.* 90 (12): 905-913. doi: 10.2471/BLT.12.105445

[២] Lim C., Takahashi E., Hongs wan M., et al (2016). “Epidemiology and burden of multidrug-resistant bacterial infection in a developing country”. *eLife.* 5 (e18082). doi: 10.7554/eLife.18082

៣ “Antibiotics Smart Use in Thailand”. *reactgroup.org.*

## ការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ

*(នាម)* គឺជាការសម្របសម្រួលសកម្មភាព ដើម្បីលើកកម្ពស់ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ ក្នុងគោលបំណងជួយសង្គ្រោះអ្នកជំងឺឱ្យបានធូរស្បើយ កាត់បន្ថយឱកាសរបស់បាក់តេរីមិនឱ្យស៊ាំនឹងឱសថ និង កាត់បន្ថយការរីករាលដាលនៃបាក់តេរីស៊ាំនឹងឱសថអង់ទីប៊ីយោទិកច្រើនមុខ។ [១]

> “ការអនុវត្តការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ នៅមន្ទីរពេទ្យ និងសហគមន៍អាចជួយជីវិតមនុស្សជាច្រើន។”

> “កម្មវិធីការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ គួរត្រូវបានណែនាំដល់មន្ទីរពេទ្យ ឱសថស្ថាន និងសហគមន៍។”

### ចំណុចគួរស្វែងយល់

### របៀបនៃការអនុវត្តការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវ

ការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវមានគោលបំណងកាត់បន្ថយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ និងលើសកម្រិត។ ការប្រើប្រាស់ឱសថអង់ទី

ប៊ីយោទិកបានត្រឹមត្រូវអាចរក្សាប្រសិទ្ធភាពឱសថអង់ទីប៊ីយោទិកបានយូរអង្វែង កាត់បន្ថយការបង្ករោគដោយមេរោគស៊ាំនឹងឱសថអង់ទីប៊ីយោទិកនៅលើអ្នកជំងឺ និងជួយអ្នកជំងឺជៀសផុតពីផលរំខាន នៃការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនចាំបាច់។ មន្ទីរពេទ្យ និងស្ថាប័នដទៃ បានអនុវត្តគោលការណែនាំក្នុងការធ្វើរោគវិនិច្ឆ័យជំងឺ ដើម្បីធានាបានការព្យាបាលត្រឹមត្រូវលើការបង្ករោគដោយវីរុស និងបាក់តេរី។

<u>**មិនមែនតែបុគ្គលិកសុខាភិបាលដែលជាអ្នកដើរតួនាទីក្នុងការជ្រើសរើសឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវនោះទេ សាធារណជនក៏មានតួនាទីយ៉ាងសំខាន់ផងដែរ។**</u> អ្នកអាចជួយលើកកម្ពស់ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកបានត្រឹមត្រូវដូចខាងក្រោម៖[២]

- យល់ដឹងពីមូលហេតុ ឬមូលហេតុដែលអាចបង្កឱ្យអ្នកមានជំងឺ និងមិនស្នើសុំឱសថអង់ទីប៊ីយោទិកប្រសិនបើមិនចាំបាច់
- មានការរស់នៅស្អាត និងអនាម័យ ហើយជៀសវាងការបរិភោគអាហារ និងពិសាទឹកមិនស្អាត
- ត្រូវប្រាកដថាអ្នក និងគ្រួសារអ្នកបានចាក់វ៉ាក់សាំងតាមការណែនាំ
- ធ្វើតាមការណែនាំរបស់វេជ្ជបណ្ឌិត និងប្រើឱសថអង់ទីប៊ីយោទិកតាមវេជ្ជបញ្ជា
- មិនត្រូវប្រើឱសថអង់ទីប៊ីយោទិកដែលនៅសល់ ឬក៏យកពីអ្នកដទៃ។

**ពាក្យទាក់ទង៖** ការជ្រើសរើសឱសថប្រឆាំងមេរោគបានត្រឹមត្រូវ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកជំនួសវៃ ការប្រើប្រាស់ឱសថដែលសមស្រប ចំណេះដឹងអំពីឱសថអង់ទីប៊ីយោទិក

## សេចក្តីយោង

[១] APIC. "Antibiotic stewardship". *Apic.org.* Date access: 20 August 20, 2018

[២] Mayo Clinic (2017). "Antibiotics: are you misusing them". *Mayoclinic.org*

# ជំពូក៦៖ មីក្រុប

## បាក់តេរី

*(នាម)* ជាអតិសុខុមកាយតូចៗមានជីវិតដែលរកឃើញគ្រប់ទីកន្លែង ហើយមិនអាចមើលឃើញនឹងភ្នែកទទេបានទេ។ បាក់តេរីជាភាវៈរស់ដែលមានកោសិកាតែមួយ និងមិនមានណ្វៃយ៉ូ(nucleus)។

> “បាក់តេរីអាចបំបែកខ្លួនបានយ៉ាងឆាប់រហ័ស។ ពេលដែលពួកវាស្ថិតក្នុងខ្លួនយើង វាអាចបញ្ចេញសារជាតិពុល ដែលធ្វើឱ្យយើងមានអារម្មណ៍មិនស្រួលខ្លួន។ ជំងឺដែលបង្កដោយបាក់តេរីមានដូចជា ការបង្ករោគក្នុងឈាម ជំងឺរលាកសួត និងការពុលចំណីអាហារជាដើម។”

> “បាក់តេរីត្រូវបានយកទៅប្រើប្រាស់នៅក្នុងការផលិតឈីស (Cheese) និងទឹកដោះគោជូរ តាមរយៈការបំបែកសារធាតុគីមី។ បាក់តេរីក៏ត្រូវបានយកទៅប្រើប្រាស់ក្នុងការផលិតឱសថអង់ទីប៊ីយោទិក និងសារធាតុគីមីផ្សេងទៀតផងដែរ។”

# ចំណុចគួរស្វែងយល់

## បាក់តេរីល្អ និងបាក់តេរីអាក្រក់

បាក់តេរីគឺជាភាវៈមានជីវិតមួយដែលលេចឡើងនៅលើភពផែនដីមុនគេ។ វាជាអំបូរសារពាង្គកាយជម្ពូតាមួយដែលរស់នៅក្នុងបរិយាកាស ក្នុងដី រុក្ខជាតិ និងស្ថិតនៅលើគ្រប់អ្វីៗទាំងអស់ និងក្នុងទឹកផងដែរ។ បាក់តេរីអាចតោងជាប់លើអ្នក តាមរយៈការចាប់ដៃគ្នា ឬការចាប់កាន់សោរទ្វារជាដើម។

បាក់តេរីល្អជាច្រើន បានជួយបំបែកសារពាង្គកាយសត្វ និងរុក្ខជាតិស្លាប់។ នៅក្នុងវិស័យឧស្សាហកម្ម បាក់តេរីផ្ដល់អត្ថប្រយោជន៍ក្នុងការបន្សុទ្ធទឹកស្អុយ និងសំអាតប្រេងកំពប់ផងដែរ។ បាក់តេរីមួយចំនួនទៀតរស់នៅក្នុងពោះវៀនមនុស្ស វាក៏បានជួយបំបែកចំណីអាហារ និងជួយបំផ្លាញការបង្កជំងឺមួយចំនួនដែលបង្កដោយអតិសុខុមកាយ និងផ្ដល់សារជាតិបំប៉នផងដែរ។

យ៉ាងណាក៏ដោយ បាក់តេរីក៏បង្កគ្រោះថ្នាក់ដល់មនុស្សផងដែរ។ វាអាចបង្កជំងឺជាច្រើនដូចជា៖ ជំងឺរលាកសួត (ឧទាហរណ៍ បង្កដោយបាក់តេរី *Streptococcus pneumoniae*) ជំងឺរលាកស្រោមខួរក្បាល (ឧ. បង្កដោយបាក់តេរី *Haemophilus influenza*) ជំងឺរលាកបំពង់ក (ឧ. បង្កដោយ Group A *Streptococcus*) និងការពុលចំណីអាហារ (ឧ. បង្កដោយ *Escherichia coli* និង *Salmonella*)។ ដោយសារបាក់តេរីអាក្រក់ទាំងនេះហើយ គឺជាមូលហេតុ

ដែលយើងគ្រប់គ្នាត្រូវលាងសម្អាតដៃ បោសសម្អាតផ្ទះបាយ និងបន្ទប់ទឹកឱ្យបានត្រឹមត្រូវ។

ជាធម្មតា បាក់តេរីរស់នៅយ៉ាងរញ៉េរញ៉ៃក្នុងមជ្ឈដ្ឋានជុំវិញ។ បាក់តេរី និងផ្សិតខ្លះបង្កើតសារធាតុឱសថអង់ទីប៊ីយោទិក ដើម្បីសម្លាប់ ឬរារាំងការលូតលាស់បាក់តេរីផ្សេងទៀត ដែលជាគូប្រជែងក្នុងការរស់នៅរបស់ពួកវា។ បាក់តេរីខ្លះអាចបន្សាំខ្លួនវាឱ្យស៊ាំទៅនឹងឱសថអង់ទីប៊ីយោទិក ដូច្នេះពួកវាអាចរស់នៅបានយូរ។

ទោះបីយ៉ាងណាក៏ដោយ នៅពេលមនុស្សប្រើប្រាស់ឱសថប្រឆាំងមេរោគមិនត្រឹមត្រូវ ឬលើសកម្រិត ការផ្លាស់ប្ដូរខ្លួនរបស់បាក់តេរីកាន់តែរហ័ស និងវត្តមានរបស់អតិសុខុមកាយដែលស៊ាំនឹងឱសថប្រឆាំងមេរោគកាន់តែច្រើន ហើយការព្យាបាលការបង្ករោគកាន់តែលំបាកជាងមុន។ យើងត្រូវតែកាត់បន្ថយការបង្កហានិភ័យនៃបាក់តេរីដែលកំពុងតែវិវត្តខ្លួនទៅជាស៊ាំនឹងឱសថ ដោយកាត់បន្ថយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងមិនត្រឹមត្រូវនេះ ក៏ដូចជាការបង្ការការបង្ករោគផងដែរ។

សរុបមក មិនត្រូវសម្លាប់បាក់តេរីល្អ ដោយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត និងមិនត្រឹមត្រូវទេ។

**ពាក្យទាក់ទង៖** ឱសថអង់ទីប៊ីយោទិក ភាពស៊ាំនឹងឱសថអង់ទីប៊ីយោទិក ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ

## ផ្សិត

*(នាម)* ជាធម្មតា វាជាអតិសុខុមកាយមានជីវិត ដែលមិនអាចមើលឃើញនឹងភ្នែកទទេបានទេ។ ប៉ុន្តែ ផ្សិតទាំងនោះអាចផ្តុំគ្នាច្រើនបង្កើតជាបណ្តុំផ្សិត(mould)ដែលអាចមើលឃើញនឹងភ្នែកផ្ទាល់បាន។ ផ្សិតជាភាវៈមានជីវិតដែលមានកោសិកាតែមួយ និងមានស្នៀយ៉ូមួយ។

> “Mushrooms, moulds, yeasts, និង mildews គឺជាឧទាហរណ៍នៃផ្សិត។”

> “ប្រភេទផ្សិតខ្លះគឺជាធាតុបង្កជំងឺដល់សត្វ មនុស្ស និងរុក្ខជាតិ។”

### ចំណុចគួរស្វែងយល់

### តើឱសថអង់ទីប៊ីយោទិកជះឥទ្ធិពលដល់ការបង្ករោគដោយមេរោគផ្សិតយ៉ាងដូចម្តេច?

ការបង្ករោគដោយសារមេរោគផ្សិតទូទៅដែលមនុស្សគ្រប់គ្នាបានដឹងមានដូចជា ជំងឺ Athlete’s foot (ជំងឺអត្តលិតហ្វូត) ជំងឺស្រែង និងការបង្ករោគដោយមេរោគផ្សិតនៅទ្វារមាសជាដើម។ វាជាអំបូរសារពាង្គកាយធម្មតាមួយដែលរស់នៅក្នុងខ្យល់ ក្នុងដី រុក្ខជាតិ និងក្នុងទឹក។ ផ្សិតខ្លះបន្តពូជតាមរយៈស្ព័រតូចៗនៅក្នុងខ្យល់អាកាស។ អ្នកអាចដកដង្ហើមស្រូបយកស្ព័រ ឬពួកវាអាចទំលាប់នឹងខ្លួនរបស់អ្នក។ អ្នកអាចនឹងប្រឈមខ្ពស់ទៅនឹងការបង្ករោគធ្ងន់ធ្ងរដោយសារមេរោគផ្សិត ប្រសិនបើប្រព័ន្ធភាពស៊ាំរបស់អ្នកខ្សោយ (ឧ. ការបង្ករោគដោយវីរុសហ៊ីវ (HIV)) ឬក៏អ្នកប្រើប្រាស់ឱសថអង់ទីប៊ីយោទិក។ ឱសថអង់ទីប៊ីយោទិកមិនអាចសម្លាប់មេរោគផ្សិតបានទេ តែពួកវាសម្លាប់បាក់តេរី។ ឧទាហរណ៍នៅតំបន់ទ្វារមាស ប្រសិនបើបាក់តេរីដែលកើតឡើងពីធម្មជាតិត្រូវបានសម្លាប់ដែលពួកវាជាអ្នកការពារពីការបង្ករោគ ដូច្នេះមេរោគផ្សិតអាចនឹងរីកដុះដាល និងអាចបង្ករោគនៅទីតាំងនោះ។

ការបង្ករោគដោយសារមេរោគផ្សិតនៅទ្វារមាស គឺជាផលវិបាកទូទៅមួយដែលបណ្តាលមកពីការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក។ ការបង្ករោគនេះអាចវិវត្តក្នុងអំឡុងពេលឬក្រោយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកសម្រាប់ព្យាបាលជំងឺដទៃទៀតដូចជា ជំងឺរលាកបំពង់ក ជាដើម។ ដូច្នេះយើងគួរប្រើឱសថអង់ទីប៊ីយោទិក នៅពេលដែលយើងពិតជាត្រូវការវាចាំបាច់ប៉ុណ្ណោះ។ យើងគ្រប់គ្នាគួរតែឈប់ប្រើប្រាស់ឱសថអង់ទីប៊ីយោទិកលើសកម្រិត ឬក៏មិនត្រឹមត្រូវ។

ការបង្ករោគដោយសារមេរោគផ្សិតនៅក្នុងសួតអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរ និងបង្កឱ្យមានរោគសញ្ញាដែលស្រដៀងនឹងជំងឺផ្សេងៗ ដូចជាជំងឺផ្តាសាយធំ ឬជំងឺរបេងជាដើម។ អ្នកគួរតែពិចារណាអំពីលទ្ធភាពនៃការបង្ករោគដោយសារ

មេរោគផ្សិត នៅពេលអ្នកមានរោគសញ្ញានៃជំងឺរលាកសួត ហើយមិនបានធូរស្បើយជាមួយនឹងការប្រើប្រាស់ឱសថអង់ទីប៊ីយោទិក។ ការធ្វើតេស្តរកមើលការបង្ករោគដោយមេរោគផ្សិតឱ្យបានលឿនអាចកាត់បន្ថយការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកដោយមិនចាំបាច់ និងអនុញ្ញាតឱ្យអ្នកចាប់ផ្តើមព្យាបាលជាមួយឱសថប្រឆាំងមេរោគផ្សិតវិញប្រសិនបើចាំបាច់។

**ពាក្យទាក់ទង៖** ឱសថប្រឆាំងមេរោគផ្សិត ឱសថប៉េនីស៊ីលីន ការប្រើប្រាស់ឱសថអង់ទីប៊ីយោទិកមិនត្រឹមត្រូវ

## សេចក្តីយោង

១ CDC (2017). “Fungal Infections- 10 Questions to protect your health.” *Cdc.gov*

## វីរុស

(នាម) ជាធម្មតា វាគឺជាអតិសុខុមកាយតូចៗគ្មានជីវិត ដែលឃើញមានគ្រប់ទីកន្លែង និងមិនអាចមើលឃើញនឹងភ្នែកទទេបានទេ។ វីរុសជាភាវៈរស់គ្មានកោសិកា និងត្រូវបានចាត់ទុកជាសារពាង្គកាយមិនមានជីវិត។ វាត្រូវការរស់នៅជាមួយកោសិកាបញ្ញើដែលមានជីវិត ដើម្បីរស់ និងបំបែកខ្លួន។

> “ឱសថអង់ទីប៊ីយោទិកមិនមានឥទ្ធិពលទៅលើវីរុសទេ។ ប្រភេទឱសថប្រឆាំងវីរុសខ្លះអាចរកទិញបានដែលអាចយកទៅព្យាបាលការបង្ករោគដោយវីរុសធ្ងន់ធ្ងរបាន ប៉ុន្តែពេលខ្លះវីរុសទាំងនោះក្លាយជាស៊ាំនឹងឱសថប្រឆាំងវីរុសទៅវិញ។”

> “ឧទាហរណ៍ជំងឺបង្កដោយវីរុសមានដូចជាជំងឺផ្តាសាយធម្មតា ជំងឺផ្តាសាយធំ ជំងឺអុតស្វាយ និងជំងឺកញ្ជ្រិលជាដើម។”

### ចំណុចគួរស្វែងយល់

**ហេតុអ្វីបានជាឱសថអង់ទីប៊ីយោទិកមិនមានប្រសិទ្ធភាពលើវីរុស?**

ឱសថអង់ទីប៊ីយោទិកគឺជាឱសថដែលប្រើសម្រាប់ព្យាបាលការបង្ករោគដោយបាក់តេរី។ វាមានគោលដៅទៅលើ ស

ម្ព័ន្ធកោសិកាដែលមាននៅក្នុងបាក់តេរីតែប៉ុណ្ណោះ។ វីរុសមានភាពខុសប្លែកពីបាក់តេរី។ ពួកវារស់ និងបំបែកខ្លួននៅក្នុងកោសិការបស់មនុស្ស ដោយសារពួកវាមិនអាចបំបែកខ្លួននៅខាងក្រៅកោសិកាបញ្ញើបានឡើយ។ ឱសថអង់ទីប៊ីយោទិកខ្លះរារាំងដល់ជញ្ជាំងកោសិកានៃបាក់តេរី និងឱសថអង់ទីប៊ីយោទិកផ្សេងទៀតរារាំងការសំយោគប្រូតេអ៊ីននៅក្នុងកោសិកាបាក់តេរី។ រចនាសម្ព័ន្ធនេះមិនមាននៅក្នុងវីរុសទេ។ [១]

ការបង្ករោគដោយវីរុសខ្លះអាចព្យាបាលជាសះស្បើយជាមួយឱសថប្រឆាំងវីរុស។ ឧទាហរណ៍ វីរុស Varicella Zoster Virus (herpes zoster) និងវីរុសបង្កជំងឺរលាកថ្លើមប្រភេទ C ។ សម្រាប់វីរុសប្រភេទផ្សេងទៀត ដូចជាវីរុសបង្កជំងឺរលាកថ្លើមប្រភេទ B និងវីរុសហ៊ីវ(HIV) យើងមានឱសថដើម្បីបង្ក្រាបដែលធ្វើឱ្យពួកវាមិនផ្ដល់ហានិភ័យដល់អ្នកជំងឺ និងធ្វើឱ្យវីរុសនេះមិនងាយចម្លងទៅអ្នកជំងឺដទៃទៀត។

ទោះបីជាយ៉ាងណា មានវ៉ាក់សាំងជាច្រើនប្រឆាំងនឹងវីរុសជាក់លាក់។ វ៉ាក់សាំងទាំងនោះ បានទៅភ្ញោចប្រព័ន្ធភាពស៊ាំរាងកាយ ដើម្បីបង្កើតអង់បឌិបក្ខប្រាណ (អង់ទីករ)។ ពេលដែលអង់បឌិបក្ខប្រាណ (អង់ទីករ)ទាំងនោះបានស្គាល់វីរុសនៅក្នុងរាងកាយ ហើយនឹងបញ្ឈប់សកម្មភាពរបស់វីរុសនោះ មុនពេលពួកវាបង្កឱ្យមានជំងឺ។ វិធីសាស្ត្រដ៏ល្អ គឺចាក់វ៉ាក់សាំងដើម្បីជួយដល់ការបង្ការការបង្កជំងឺដូចជាជំងឺកញ្ជ្រិល និងជំងឺផ្តែផ្តួត។ ដើម្បីអានបន្ថែម **សូមចុចទីនេះ។**

**ពាក្យទាក់ទង៖** ឱសថប្រឆាំងវីរុស ជំងឺផ្ដាសាយធំ ជំងឺផ្ដាសាយធម្មតា

## សេចក្ដីយោង


[១] BBC Science (2013). “Why can’t we beat viruses?” *BBC.com*

## សេចក្តីថ្លែងអំណរគុណ

វចនានុក្រមស្តីពីភាពស៊ាំនឹងឱសថប្រឆាំងមេរោគបានទទួលការឧបត្ថម្ភដោយ The Wellcome Trust Provision សម្រាប់ពានរង្វាន់លើការចូលរួមរបស់សាធារណជន។ ពួកយើងសូមថ្លែងអំណរគុណដ៏ធំក្រៃលែងចំពោះការជួយជ្រុមជ្រែងពីអ្នកនិពន្ធវចនានុក្រមនេះ។

## បកប្រែនិងកែសម្រួលវចនានុក្រមជាភាសាខ្មែរដោយ

Paul Turner MB BS, PhD, FRCPCH, FRCPath
Director, Cambodia Oxford Medical Research Unit, Siem Reap, Cambodia; Associate Professor, University of Oxford, UK

**លោក កង រ៉ូយ៉ា**
ប្រធានការិយាល័យរដ្ឋបាល នៃអង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ កម្ពុជា អុកស្វឹត ខេត្តសៀមរាប ប្រទេសកម្ពុជា

**លោក វេជ្ជបណ្ឌិត មីលីយ៉ា ធីល**
Clinical Microbiologist នៃអង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ កម្ពុជា អុកស្វឹត ខេត្តសៀមរាប ប្រទេសកម្ពុជា

**លោក លាប ផាណា**
បុគ្គលិកជំនួយការផ្នែកស្រាវជ្រាវ នៃអង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ កម្ពុជា អុកស្វឹត ខេត្តសៀមរាប ប្រទេសកម្ពុជា

**លោក សុពុធី ច័ន្ទសុវណ្ណារ៉ា**
បុគ្គលិកជំនួយការផ្នែកស្រាវជ្រាវ នៃអង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ កម្ពុជា អុកស្វឹត ខេត្តសៀមរាប ប្រទេសកម្ពុជា

**លោក ប៉ាវ វិចិត្រ**
ជំនួយការបញ្ចូលទិន្នន័យ នៃអង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ កម្ពុជា អុកស្វឹត ខេត្តសៀមរាប ប្រទេសកម្ពុជា

ប្រសិនបើអ្នកមានមតិយោបល់ សំណូមពរ ឬសំណួរអំពីវចនានុក្រមនេះ សូមទំនាក់ទំនងតាមរយៈអ៊ីមែល៖ ravikanya@tropmedres.ac និង direk@tropmedres.ac